ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្តីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៧-១៨
Vol. 14 17 - 18

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# បញ្ជីរឿង


| | |
|---|---|
| | ទំព័រ |
| ១ — វិទ្យុធម្មទេសនា កណ្ឌទី ៩ លោកអាចារ្យ យូរ-អ៊ុន, ក្រុមជំនុំប្រែព្រះត្រៃបិដក សំដែង . . . . . . . . . . . . . . . . . . . . . . | ១ |
| ២ — ច្បាប់ប្រុស ចំឡងចេញបោះពុម្ពផ្សាយ តាមច្បាប់សាស្ត្រាស្លឹករឹត . . . . . | ១២ |
| ៣ — បិសាចស្នេហា យ. និពន្ធមន្ត្រី អ្នកតែងសេចក្តី នៅព្រះរាជបណ្ណាល័យ ជាអ្នកតែង (តមកនឹងចប់) . . . . . . . . . . . . . . . . . . . . . | ២០ |
| ៤ — កុម្ភជាតក លោកគ្រូអាចារ្យ ឈឹម-ស៊ុម គ្រូបង្រៀននៅសាលាបាលីជាន់ខ្ពស់ ប្រែនិងរៀបរៀងពីគម្ពីរខុទ្ទកនិកាយ តិំសនិបាត (តមកនឹងចប់) . . . . . . | ៤២ |
| ៥ — រឿងព្រេងខ្មែរ: “រឿងស្ត្រីឈ្មោះក្រង់នឹងស្វាមី” . . . . . . . . . . . . | ៦២ |

# TABLE DES MATIÈRES


Pages

1. Vidyudhammadesanā (conférence faite à la Radio Phnom-Penh), par le vénérable Achar YOU-OUN, membre de la Commission du Tripitaka.............................. 1

2. Chbab Prôs (Conseils aux fils).............................. 12

3. Bisach-Snéhā, roman khmer par Kh. NIBANDHA-MANTRI, 2e partie (suite et fin).............................. 20

4. Kumbhajātaka, traduit du pāli par le Vénérable CHHIM-SOUM, professeur à l'École supérieure de Pāli, 2e partie(suite et fin). 42

5. Conte populaire cambodgien inédit: " Une femme fidèle à son mari ".............................. 62

# អនាមតធម៌

## អាចារ្យ យូរ-អ៊ុន ក្រុមជំនុំព្រះត្រៃបិដក
## សំដែងដាក់វិទ្យុ លើកទី៩

ក្នុងថ្ងៃ ១៥ កើតខែវិសាខ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥
ត្រូវនឹងថ្ងៃ ២៩ អាវ្រិល ឆ្នាំ១៩៤២

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពនឹងសំដែងអនាមតធម៌ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញានៃពុទ្ធសាសនិកជន ។ មុននឹងសំដែងញែកបំបែកចេញជាមាតិកានៃធម៌នេះ សូមអធិប្បាយអំពីពាក្យថា អនាមតធម៌ សិន ។

ពាក្យថា អនាមតធម៌ ប្រែថា "ធម៌ធ្វើសត្វមិនឲ្យស្លាប់" តែសូមកុំចូលចិត្តថា ធម៌នោះជាផ្ទស់ទស់ជីវិតសត្វឲ្យរស់នៅអស់កប្បកល្បឡើយ; ព្រោះជីវិតរបស់សត្វក្នុងលោកនេះ ទោះថោកក្តី ថ្លៃក្តី គ្មានអ្វីទស់ទប់បានទេ, តែងតែវិនាសបាត់បង់ទៅដូចៗគ្នាទាំងអស់ ។ ត្រង់ពាក្យថា "ធម៌ធ្វើសត្វមិនឲ្យស្លាប់" ក្នុងទីនេះ ត្រូវសំគាល់យកគុណធម៌មួយយ៉ាងដែលធ្វើមិនឲ្យស្លាប់កេរ្តិ៍ឈ្មោះ មិនឲ្យមានគ្រោះថ្នាក់ គឺជាអ្នកលេចឈ្មោះបោះសំឡេង មិនបាត់ឈ្មោះសូន្យឈឹងដូចគេបាញ់ព្រួញទៅក្នុងទីងងឹត, បើទុកជាជីវិតស្លាប់ទៅ ក៏កេរ្តិ៍ឈ្មោះនៅពិរោះមានគេគោរពរាប់គេយកជាតម្រាប់តាមស្អិត ដូចមានសុភាសិតថា "រស់ក៏គាប់ ងាប់

ក៏គួរ" គួយ៉ាងដូចអ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើម កាលទ្រង់គង់នៅមាននៅឡើយ ទ្រង់បានបំពេញអនាមតធម៌ក្នុងសន្តាន ក៏បានទីជាសារស្ពានស្ពារក្នុងលោក សូម្បីព្រះអង្គបរិនិព្វានបាត់ទៅពិត តែគុណ-ធម៌សុចរិតដែលព្រះអង្គប្រព្រឹត្តឥតបាត់បង់ទៅជាមួយព្រះអង្គទេ នៅផ្សាយកេរ្តិ៍កិត្តិគុណរបស់ព្រះអង្គស្ទើរសព្វប្រទេស ហាក់ដូចជាព្រះអង្គមិនមែនបរិនិព្វាន នៅមានព្រះជន្មទ្រង់និមន្តទេសនាទូន្មានសត្វតាមធម្មតា, ទាំងនេះក៏មកពីព្រះអង្គមានអនាមតធម៌ក្នុងព្រះខន្ធសន្តាន ។

អនាមតធម៌នោះមានប្រភេទចែកជា ៥ ប្រការ ដោយពុទ្ធភាសិតថា

យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ឯតទរិយា សេវន្តិ ឯតំ លោកេ អនាមតំ ។

សេចក្តីថា: គុណធម៌ ៥ ប្រការគឺ សច្ចៈ១ ធម៌១ អហឹសា១ សញ្ញមៈ១ ទមៈ១ មានក្នុងបុគ្គលណា ព្រះអរិយទាំងឡាយរមែងគប់រកបុគ្គលនោះ, គុណធម៌មានសច្ចៈជាដើមនេះ ឈ្មោះថាអនាមតធម៌ តែងប្រតិស្ឋានទៅក្នុងលោក ។

ឯគុណធម៌ទាំង ៥ ប្រការក្នុងព្រះគាថានេះ មានមកក្នុងទីដទៃៗជាច្រើន លោកសំដែងអធិប្បាយទុកដោយឧបរិមន័យខ្លះ ដោយហេដ្ឋិម-ន័យខ្លះ អនុលោមតាមហេតុខ្លះ, ក្នុងទីនេះ នឹងអធិប្បាយឲ្យសមគួរដល់ភាពជាអនាមតធម៌ ដើម្បីជាសាធារណប្រតិបត្តិតទៅ ។

១ — ការប្រព្រឹត្តកាយវាចាព្រមដោយចិត្តពិត ៗ ឈ្មោះថាសច្ចៈ គឺថាបើប្រព្រឹត្តធ្វើអ្វីដោយកាយក្តី ដោយវាចាក្តី ក៏ឲ្យចិត្តព្រមធ្វើផង ទើបឈ្មោះថាសច្ចៈ, បើធ្វើតែកាយនឹងវាចា ចំណែកចិត្តមិនព្រមធ្វើ ដូចថ្វាយបង្គំសោះតែកុំឲ្យគេថា ពោលវាចាសោះតែមិននិយាយរក ដូច្នេះឲ្យឈ្មោះថាសច្ចៈមិនបាន ។ បើពោលដោយសេចក្តីអធិប្បាយ បានដល់ភាពជាអ្នកកាន់ទៀងត្រង់នឹងសំឡាញ់ មិនទ្រុស្តមិត្តមានចិត្តស្មោះត្រង់នឹងគ្នា, ទៀងត្រង់ចំពោះកាលវេលាដែលជាពេលត្រូវចូលត្រូវចេញ, ទៀងត្រង់ចំពោះកិច្ចការដែលជាមុខក្រសួងខ្លួនត្រូវធ្វើ មិនចាប់នេះចាប់នោះមិនផ្តោះត្រង់ណា, ទៀងត្រង់នឹងចៅហ្វាយនាយមិនមានគំនិតវៀចវេរ មានកតញ្ញូកតវេទីចំពោះលោកអ្នកមានគុណមិនរំលុបបំភ្លេចគុណលោកចោល, ទាំងនេះហៅថាសច្ចៈ ។ សច្ចៈនេះប្រើបានទាំងខាងល្អទាំងខាងអាក្រក់ តែក្នុងទីនេះសំដៅយកសច្ចៈដែលជាប្រយោជន៍ផង ជាធម៌ផង ។ គុណធម៌នេះជាសំខាន់មួយក្នុងកិច្ចការរបស់ពួកមនុស្ស, មែនពិត កិច្ចការគ្រប់យ៉ាងមិនថាផ្លូវលោកឬផ្លូវធម៌ទេ ដែលនឹងសម្រេចកើតការដូចប្រាថ្នាទៅបាន ក៏ព្រោះមានសច្ចៈជាគ្រឿងជួយទំនុកបម្រុង, ព្រោះធ្វើអ្វីធ្វើពិត គិតអ្វីគិតមែន រៀនអ្វីរៀនមាំ រមែងបានទទួលផលពិតដូចគ្នា បើវៀរចាកសច្ចៈចេញហើយ ផលមិនបានសម្រេចទៅតាមបំណងឡើយ ។ បុគ្គលអ្នកកាន់សច្ចៈទៀងត្រង់ប្រៀបដូចបានកែវដ៏មានដំឡៃ ព្រោះអាចនឹង

ដ៏កនាំប្រជុំជនឲ្យមានសេចក្តីស្រឡាញ់គោរពរាប់អាន មានកេរ្តិ៍ឈ្មោះក្រអូបសុះសាយសព្វទិស ហេតុនោះទើបព្រះទសពលទ្រង់ត្រាស់ថា សច្ចេន កិត្តឹ បប្បោតិ "បុគ្គលនឹងមានកេរ្តិ៍ឈ្មោះក៏ព្រោះសច្ចៈ" ។ មួយទៀត សច្ចៈនេះ ជាបច្ច័យឲ្យសម្រេចប្រយោជន៍ខ្លួនឯងនិងប្រយោជន៍បុគ្គលដទៃ បណ្តុះសេចក្តីរីករាយជាទីចាប់ចិត្តចាប់ថ្លើមនៃគ្នានឹងគ្នាព្រោះថា ជារសឆ្ងាញ់ដ៏សំខាន់ជាងរសឯទៀតដែលមានក្នុងលោកនេះ, រសអាហារសូម្បីឆ្ងាញ់ពិសាត្រឹមណា ក៏គង់មិនជាទីគាប់ចិត្តរបស់មនុស្សទូទៅ សូម្បីត្រូវមាត់ខ្លះៗ ក៏គង់មានវេលានឿយណាយ, ចំណែករសគឺសច្ចៈនេះ អាចឆ្ងាញ់ចាប់ចិត្តមនុស្សគ្រប់ជាតិគ្រប់ជាន់ ជារសដែលមិនចេះទ្រាន់មិនជិនណាយ នឹកឡើងកាលណា ចិត្តក៏រីករាយពេលនោះ សមដូចពុទ្ធភាសិតថា សច្ចំ ហវេ សាទុតរំ រសានំ "សច្ចៈការកាន់ទៀងត្រង់ ជារសឲ្យសម្រេចប្រយោជន៍ជាងរសទាំងឡាយ" ។ សច្ចៈនេះជាគុណអាចធ្វើបុគ្គលឲ្យជាទីគោរពកោតក្រែងនៃជនដទៃ ដូចសេចក្តីដែលពោលមក ហេតុនោះទើបឈ្មោះថា អនាមគធម៌ ដោយប្រការដូច្នេះ ។

២ – ពាក្យថា ធម៌ៗនេះ ជាពាក្យប្រើទូទៅទាំងចំណែកល្អទាំងចំណែកអាក្រក់និងជាកណ្តាល ។ ក្នុងទីនេះ 'សំដៅយកសភាវៈដែលល្អ' ហៅថាធម៌ តែធម៌នុះមានច្រើនក្រៃពេក សូម្បីគុណ ៤ ប្រការក្នុងក្រម

អនាមតធម៌នេះក៏ហៅថាធម៌ដែរ, តែកាលបើលោកលើកធម៌មកចាត់ជាអង្គមួយដូច្នេះ ត្រូវសំគាល់ដល់គុណដទៃវិញ ក្នុងទីនេះនឹងលើកយកគារវធម៌មកសំដែង ។ ពាក្យថា គារវៈ ប្រែថា "សេចក្ដីគោរព" បានដល់ការក្រាបសំពះ បុគ្គលដែលគួរក្រាបសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរឲ្យ ប្រាប់ផ្លូវដល់បុគ្គលដែលគួរប្រាប់ ធ្វើសក្ការបូជាដល់បុគ្គលដែលគួរធ្វើ ។ គារវធម៌នេះ ជាគុណសំខាន់របស់ពួកជនគ្រប់ជាន់ ជាគ្រឿងអបរម្យសេចក្ដីសាមគ្គីឲ្យរឹងប៉ឹង ទាំងជាគុណនាំឲ្យកើតសួស្ដីជ័យមង្គល ។ មែនពិត ប្រជុំជនដែលរួមគ្នានៅជាពួកៗ ចាប់តាំងអំពីត្រកូលមួយរហូតដល់ប្រទេសមួយ តែងមានអធ្យាស្រ័យចិត្តគំនិត និងការប្រព្រឹត្តផ្សេងៗគ្នា, ព្រោះហេតុនោះក្នុងសមាគមមួយៗ គេត្រូវតាំងមនុស្ស ១ នាក់ឲ្យជាប្រមុខ ជាអ្នកគ្រប់គ្រងមើលសេចក្ដីសុខទុក្ខគ្រប់ប្រការ, ជនក្រៅអំពីនេះ ត្រូវមានសេចក្ដីគោរពរាប់អានជឿស្ដាប់ ធ្វើតាមពាក្យបង្គាប់របស់អ្នកជាប្រមុខ, ឯជនជាអធិបតីក៏គប្បីគោរពច្បាប់សម្រាប់ប្រព្រឹត្តទៅរកអ្នកតូចដែលហៅថាយុត្តិធម៌ មិនលំអៀងដោយអំណាចអគតិទាំង ៤ មានឆន្ទាគតិជាដើម; កាលបើសាធុជនបានតាំងខ្លួនក្នុងគារវធម៌យ៉ាងនេះ នឹងមានតែសេចក្ដីចំរើនកេរ្តិ៍ឈ្មោះយសសក្ដិដូចព្រះចន្ទក្នុងសុក្កបក្ខ (ខាងខ្នើត)តែម្យ៉ាង ៗ

ហេតុនោះទើបព្រះមហាមុនីត្រាស់ទុកក្នុងអបរិហានិយធម្មសូត្រត្រង់ខទី ៤ ថា "ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឯណាជាថេរៈ មានវ័យចំរើន ជាសង្ឃ-បិតា ជាសង្ឃបរិនាយក, ភិក្ខុនាំគ្នាធ្វើសក្ការៈគោរពរាប់អានបូជាជឿស្តាប់ពាក្យរបស់ភិក្ខុជាថេរៈនោះត្រឹមណា, នឹងមានតែសេចក្តីចំរើនត្រឹមណោះ" ។ សេចក្តីគោរពនេះ មិនមែនគ្រាន់តែជាផ្លូវប្រតិបត្តិរបស់ជនជាសាមញ្ញទេ, សូម្បីព្រះអរហន្តសម្ពុទ្ធជាកំពូលសាស្តាក្នុងត្រៃភព ក៏ទ្រង់ធ្វើសេចក្តីគោរពដែរ, ដូចនឹងឃើញបាន កាលព្រះអង្គត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណហើយថ្មីៗ ស្តេចគង់នៅក្រោមដើមអជបាល-និគ្រោធក្បែរឆ្នេរស្ទឹងនេរញ្ជរា, ទ្រង់រំពឹងឃើញថា ការមិនមានអ្នកណាជាទីគោរពជាការមិនប្រពៃ, ទើបទ្រង់ស្វែងរកបុគ្គលដែលគួរព្រះអង្គធ្វើសក្ការគោរពរាប់អាន, តែមិនបានចួបប្រទះសមណព្រាហ្មណ៍ណាមួយដែលមានគុណវិសេសជាងព្រះអង្គ, បើទុកជាដូច្នោះ, ក៏គង់ទ្រង់ធ្វើសក្ការគោរពព្រះធម៌ដែលព្រះអង្គត្រាស់ដឹងហើយ ពិតមែន ព្រះពុទ្ធទាំងឡាយ និព្វានកន្លងទៅហើយក្តី នឹងត្រាស់ឡើងក្នុងកាលខាងមុខក្តី ក្នុងកន្លុកល្បឥឡូវនេះក្តី ទ្រង់ធ្វើសេចក្តីគោរពចំពោះព្រះធម៌តែម្យ៉ាង, នេះជាទំនៀមរបស់ព្រះពុទ្ធទាំងឡាយ ។ សេចក្តីគោរពនេះ ជាគ្រឿងអលង្ការរបស់ពួកជន អាចឃុំគ្រងពួកក្រុមឲ្យតាំងនៅក្នុងសាមគ្គីរក្សា

សន្តិសុខឲ្យប្រព្រឹត្តទៅ ហេតុនោះ ទើបឈ្មោះថាអនាមតធម៌ ដោយប្រការដូច្នេះ ។

៣ – ការមិនគិតបៀតបៀនធ្វើទុក្ខធ្វើបាបដល់សត្វនិងបុគ្គលដទៃ ឈ្មោះថា អហឹសា, លោកបំណងយកមេត្តាចិត្ត គឺចិត្តដែលគិតប្រាថ្នារកសេចក្តីល្អឲ្យដល់គ្នានឹងគ្នា, បើពោលឲ្យខ្លីក៏គឺសេចក្តីប្រាថ្នាឲ្យគេបានសុខនោះឯង ។ មេត្តានេះលោកចាត់ជាព្រហ្មវិហារធម៌ គឺធម៌ជាគ្រឿងអប់មៀសន្តានរបស់អ្នកធំជាប្រធាននៃពួក, អធិប្បាយថា ជនជាធំជាអធិបតីក្នុងសមាគមមួយ ៗ រាប់តាំងអំពីត្រកូលមួយស្រុកមួយឡើងទៅ ត្រូវផ្កល់ខ្លួនក្នុងព្រហ្មវិហារធម៌ គឺត្រូវមានចិត្តមេត្តាប្រាថ្នាឲ្យអ្នកតូចមានសេចក្តីសុខ–ចំរើន, បើអ្នកតូចមានសេចក្តីទុក្ខព្រួយក៏មានចិត្តអាណិតអាសូរករុណាប្រាថ្នានឹងជួយដោះឲ្យរួចអំពីទុក្ខនោះ មិនព្រងើយកន្តើយ, កាលបើអ្នកតូចចំរើនដោយលាភយសហើយ ក៏មានមុទិតាចិត្តរីករាយជួយផ្សាយអនុមោទនា មិនគិតឫស្យាច្រណែនគ្នា, កាលបើអ្នកតូចមានសេចក្តីសុខ-ចំរើន ក៏តាំងចិត្តជាឧបេក្ខាមិនគិតបៀតបៀនឲ្យអ្នកតូចបានទុក្ខលំបាកឡើយ; អ្នកធំកាលបើតាំងនៅក្នុងមេត្តាធម៌នេះហើយ អ្នកតូចរមែងនិយមរាប់អាន, ការរាប់អាននោះជាគួអំណាច, អ្នកមានអំណាចលុះណាតែមានគេកោតក្រែងគោរពរាប់អានលើកដំកើងឲ្យជាធំជាប្រធាន

ប្រព្រឹត្តតាមទំនងមានមេត្រីយ៉ាងស្មោះអស់ពីពោះ មិនបានសេចក្តីរង្កៀសសង្ស័យ, ត្រូវតាមន័យពុទ្ធភាសិតថា វេសា ន សប្បុរិយំ លោកេ "អំណាចវែងជាធំក្នុងលោក" ។ អ្នកធំកាលតាំងខ្លួនក្នុងមេត្តានេះ រមែងជាទីរាប់អានរបស់មនុស្សទូទៅអាចនឹងគ្រប់គ្រងសមាគមនោះៗ ឲ្យតាំងនៅបានដោយសួស្តី ។ អហឹសា ការមិនបៀតបៀននេះជាគុណធម៌នាំឲ្យកើតសេចក្តីគោរពរាប់អានគ្នា ដូចបានពណ៌នាមកនេះ ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ។

៤ – ការសង្រួមរាំងខ្លួនឲ្យរួចចាកទោសដែលបណ្ឌិតគប្បីតិះដៀលឈ្មោះថា សញ្ញមៈៗ នេះ លោកខែយោងសេចក្តីផ្សេងៗគ្នា, ក្នុងទីខ្លះលោកខែប្រាប់ថាសីល ក្នុងទីខ្លះថាឥន្ទ្រិយសំវរៈ ក្នុងទីខ្លះថាសមាធិចិត្ត, តែកាលបើពោលដោយរួបរួម បានដល់ការសង្រួមរាំងខ្លួនមិនធ្វើការងារដែលបណ្ឌិតគប្បីតិះដៀលឬមិនធ្វើការងារដែលមានទោស ដោយវិធីរក្សាសីល ដោយការសង្រួមឥន្ទ្រិយឬដោយចំរើនសមាធិភាវនា ។ សញ្ញមធម៌នេះ ជាគុណសម្រាប់អ្នកធំប្រការមួយ, ក៏ដ្បិតអ្នកធំបើមិនសង្រួមរាំងខ្លួនក្នុងកិច្ចការដែលត្រូវធ្វើទេ ប្រកបតែកម្មដែលជាទោស ក៏មិនជាទីគោរពរាប់អាននៃអ្នកតូច ជាផ្លូវធ្វើឲ្យអ្នកតូចមើលងាយអស់សេចក្តីកោតក្រែង ព្រោះហេតុនោះអ្នកធំទើបត្រូវសង្រួមរាំងខ្លួនឲ្យរួចចាក

មន្ទិលសៅហ្មងដែលអ្នកប្រាជ្ញគប្បីតិះដៀល ដោយវិធីរក្សាសីល ឬដោយការសង្រួមឥន្ទ្រិយ ឬក៏ដោយការចំរើនសមាធិភាវនាដូចពោលហើយ, កាលបើសង្រួមរាំងយ៉ាងនេះ សេចក្តីអាក្រក់ទាំងមិនមានឱកាសកើតឡើងបាន ដូចពុទ្ធភាសិតថា សញ្ញមតោ វេរំ ន ចីយតិ "អ្នកសង្រួមរមែងមិនកពៀរវេរាឲ្យកើតឡើយ" ។ តអំពីនោះមកនឹងប្រសពផលផ្ទួនឲ្យជាទីគោរពរាប់អានរបស់អ្នកតូច អាចគ្រប់គ្រងនិយាយស្តីទៅកាន់អ្នកតូចបានពេញមាត់ ហេតុនោះ សញ្ញមៈ ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ។

៥- ការទប់ឃាត់ចិត្ត ការប្រាបប្រាមចិត្ត ការហ្វឹកហ្វឺនទូន្មានចិត្តឲ្យប្រាសចាកភ័យអន្តរាយ ឈ្មោះថាទមៈ ។ នេះ លោកក៏ចែងប្រាប់សេចក្តីផ្សេងៗគ្នាដែរ គឺជួនកាលលោកប្រាប់ថា បានដល់ឥន្ទ្រិយសំវរៈ ជួនកាលថាបានដល់វិបស្សនាបញ្ញា, តែបើពោលដោយប្រួម ក៏គឺការទប់ឃាត់ប្រាបប្រាមទូន្មានខ្លួនឲ្យឃ្លាតចាកការកំរើករំភើប ដែលប្រែប្រួលចិត្តដែលបណ្តាលមកអំពីសង្កិលេសធម៌ គឺរាគៈ ទោសៈ មោហៈ ឬដែលជាប់មកអំពីលោកធម៌ ដោយវិធីសង្រួមឥន្ទ្រិយ ឬក៏ដោយវិធីចំរើនវិបស្សនា ឈ្មោះថា ទមៈ ។ ធម៌នេះ ជាគុណសំខាន់សម្រាប់ជនគ្រប់ថ្នាក់ ព្រោះថាធម្មតាមនុស្សយើងបើឥតធម៌នេះក្នុងសន្តានហើយ ក្នុងពេលដែល

ត្រូវរាគៈ ទោសៈ មោហៈ ផុះផាលពុះពោរឡើង ក៏នឹងនាំចិត្តឲ្យលុះក្នុងអំណាចកិលេសនោះ ៗ ជាហេតុឲ្យហ៊ានប្រព្រឹត្តអាក្រក់ផ្លូវកាយវាចាច្រើនប្រការ, រហូតដល់ភ្លេចភូមិឋានជាតិប្រទេស មិនមានសេចក្ដីខ្មាសបាបខ្លាចបាបទេ, ក្លាយទៅជាមនុស្សមានកំហុសធំក្នុងលោក ដែលមិនជាទីគោរពរាប់អានកោតក្រែងរបស់ប្រជាជន, ក្នុងពេលដែលប្រទះលោកធម៌ ទោះជាចំណែកគួរប្រាថ្នាក្ដី មិនគួរប្រាថ្នាក្ដី ក៏នឹងទប់ឃាត់ចិត្តមិនបាន នឹងសំដែងសេចក្ដីឆេវឆាវចិត្តឬរន្ធត់បាត់ស្មារតីដែលជាចំណែកខូចភូមិរបស់មនុស្ស, បើមានគុណធម៌នេះនៅប្រចាំក្នុងចិត្តវិញ រមែងមិនគិតគិតបារម្ភញាប់ញ័រទេ បើទុកជាប្រែខ្វះក៏មិនប្លែកខុសធម្មតា ចូលក្នុងតម្រាថា “ព្រឹក្សឫសមាំត្រូវខ្យល់បោក គ្រាន់តែយោគយោកជ្រុះសន្លឹក” មួយទៀតសមដូចបាលីថា សុខេន ផុដ្ឋា អថវា ទុក្ខេន ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ “បណ្ឌិតទាំងឡាយ ទោះបីសុខនឹងទុក្ខពាល់ត្រូវហើយ ក៏មិនសំដែងអាការឡើងចុះឡើយ” ។ សេលោ យថា ឯកឃនោ វាតេន ន សមីរតិ ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា “បណ្ឌិតទាំងឡាយ តែងមិនញាប់ញ័រព្រោះនិន្ទានឹងសរសើរ ដូចភ្នំថ្មតាន់មួយមិនរញ្ជួយ ព្រោះខ្យល់ព្យុះដូច្នោះឯង ។ ទាំងនេះក៏ដោយមានទមធម៌នៅប្រចាំក្នុងចិត្ត ហេតុនោះ ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ។

ធម៌ទាំង ៥ ប្រការគឺ សច្ចៈ, ធម៌, អហឹសា, សញ្ញមៈ, ទមៈ, មានបរិបូណ៌នៅក្នុងបុគ្គលឯណា ព្រះអរិយទាំងឡាយរមែងសេពគប់បុគ្គលនោះ ធម៌មានសច្ចៈជាដើមនោះ ឈ្មោះថាអនាមតធម៌ គឺធម៌មិនចេះចាស់ឈឺស្លាប់ មានន័យដូចសេចក្ដីអធិប្បាយដោយសង្ខេបមកនេះឯង ។

អាត្មាភាពសំដែងមកក្នុងអនាមតធម៌ តបស្នងគុណសទ្ធានៃពុទ្ធសាសនិកជន ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញាបារមី សន្តតជាបប់តាមសមគួរដល់កាលវេលាត្រឹមប៉ុណ្ណេះ ។

ចប់វិទ្យុធម្មទេសនាកណ្ឌទី ៩ តែប៉ុណ្ណេះ ។

## ច្បាប់ប្រុស

### បទព្រហ្មគីត

នេះបទព្រហ្មគីត ពីព្រេងព្រឹទ្ធទុកខ្ជានាន ចែងចងជានិទាន ទុក
ត្រាទ់មើលជាច្បាប់ថ្មី ៗ ឲ្យអស់កូនចៅក្រោយ ស្តាប់កុំឲ្យភ្លេចស្មារតី
ប្រដៅទាំងប្រុសស្រី យកទុកខ្លួនគ្រប់អាត្មា ៗ ធម្មតាកើតជាមនុស្ស
ទោះស្រីប្រុសគ្រណាស់ណា ត្រិតត្រងចិន្តា ឲ្យបានដឹងសមនឹងគួរ ៗ
នឹងអស់ញាតិសន្តាន សោះគេមានពាក្យថាជួ កុំឆ្មើងកុំតែងតួ ធ្វើ
កំហោ៊ងកុំពាក្យធំ ៗ ទឹងដើរដូចកូដគ្គ ឲ្យឱនអង្គអាចបារម្ភ ឲ្យត្រូវ
ទំនងច្បាប់ក្រម គួរប្រតិបត្តិកុំឲ្យគ្គង ៗ រៀនបទរៀនបាទបាស កុំ
ច្រឡាសលើរៀមច្បង ស្រដីទំនងអ្នកផង ពាក្យឲ្យគួរកុំឯងរុំយ ៗ
អឺអើអញជាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី ដើមដៀលឲ្យអប្រិយ
ស្រដីថាកូនឥតពូជ ៗ ចាស់ទុំមិនប្រដៅ ដៅកូនចៅទើបកំខូច គេថា
កូនឥតពូជ មិនដឹងច្បាប់ទំនងចាស់ទុំ ៗ គេដៀលដល់ម៉ែឪ គេត្រ
អាស្រូវស្អុយហើ គេស្តីដើមដៀវដុំ ដំនៀលនោះដល់មកចាស់ ៗ
កុំកាចកុំស្អូតពេក កុំចំអៀករៀនរហ័ស កុំខ្លាចកុំហ៊ានណាស់ ឲ្យរំ-
ពឹងរំពៃគ្រប់ ៗ ទោះដេកឲ្យរហ័ស ភ្ញាក់មុនចាស់ដោះទៀងលុប
មុខមាត់មើលឲ្យគ្រប់ ទ្រព្យរបស់សិមដេកវិញ ៗ ស្មាម្សុីឲ្យប្រៀក
កុំបីបៀកទាំងមូលមិញ តូចធំឲ្យប្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ ៗ

ដេកយប់កុំដេកយូរ ហើយខទូរដូចគេឆាប់ សំពត់ស្បៀតឲ្យខ្ជាប់ កុំឲ្យ
អាក្រាតក្រៅខ្លួន ។ ទំនងដេកកុំទ្រមក ឲ្យលង់លក់ក្រៅពីក្បួន បើភ្ញាក់
ឲ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្លាំង ។ ប្រែប្រាណប្រងវិញ្ញាណ ខ្លាច
ក្រែងមានចោរចិត្តខ្លាំង ប្រញ្ញប្រាណប្របជញ្ជាំង ជញ្ជូនទ្រព្យលួចយក
ចេញ ។ បើឥតមោះមន្ទិល កុំឲ្យខ្ជិលដេកទៅវិញ ភ្ញាក់ហើយឲ្យក្រោក
ចេញ រកជក់ថាំស្លុមស្លា ។ ទោះពេលពន់ព្រលប់ គន់ឲ្យគ្រប់ទ្រព្យ
នានា កាំបិតខាងអាត្មា ឲ្យសិតទុកដាក់ចុងជើង ។ ប្រអប់ដាក់ទឹមស្លា
ថ្វាយទេព្តារក្សាយើង ហើយឲ្យបំពក់ភ្លើង នៅក្រានក្រៅកុំឲ្យដាច់ ។
កុំឲ្យអស់លើង លេតធេងហើយថាភ្លេច សព្វថ្ងៃមើលកុំដាច់ កុំដើរ
យកពីផ្ទះគេ ។ ថែទាំមើលជើងក្រាន ឲ្យចុះមានកុំទំនេរ បង្កាត់
បង្កើតកេរ្តិ៍ កុំប្រហែសឲ្យសូន្យសុង ។ ប្រយ័ត្នក្រែងក្រងាយ ពុំ
សប្បាយឈើពោះពុង បង្កាត់កំដៅអគ្គ អុជបំភ្លឺមើលនេះនោះ ។ មាន
កាលយប់ងងឹត ភ្លេចមិនគិតជួនកូនជុះ គ្មានភ្លើងអុជចុះ ក្រានលុះ
លេតធេង ។ រត់រកភ្លើងសស្រាក់ ព្រួយលំបាកតែខ្លួនឯង ហេតុខ្ជិលពុំ
គិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ ។ ហើយឲ្យថែទាំទឹក ទោះយប់
ព្រឹកកុំគិតងាយ ជង់ដាក់ក្អមពក់ពាយ សព្វព្រួចពាងអាងអុងធំ ។ កុំ
ឲ្យស្លុតក្អមធេង អស់លើងពីពាងធំ គ្មានសោះនោះមិនសម ជួនក្រែង
ក្រងាយយប់ថ្ងៃ ។ ទោះដើរទៅឆ្ងាយជិត កាន់កាំបិតកំដរដៃ ក្រែង

មានមែកឈើព្រៃ កាប់កាន់មកទុកជាទេស ៗ ជូនកាលក្រែងបន្លា មុតអាត្មាគ្រាន់ចាក់ជោះ ជាគ្រឿងគ្រប់មិនខុស ការសត្រូវទោះឆ្នាថ្ក ៗ ដើរព្រៃឲ្យមើលលើ ឃើញស្លឹកឈើជាបន្លែ កាន់កាប់កុំដៃទេ អង្គុយគន់មើលឆ្វេងស្ដាំ ៗ ក្រែងមានឈើព្រៃងាប់ គួរកាប់កាប់យកជាថ្នាំ ធ្វើក្រានគ្រាន់ដណ្ដាំ បាយបានឆ្អិនឆាប់ដូចចិត្ត ៗ សោះស្រីស្រដីបាន បើខុសមានមិនព្រួយចិត្ត សព្វថ្ងៃប្រុងគំនិត ថែទាំទើបគង់របស់ ៗ មាសប្រាក់ស្រូវអង្ករ ទុកឲ្យល្អកុំសប្បុរស សំចៃយកុំឲ្យអស់ មើលថែជូនខ្លួនឯងណា ៗ ស្បូវស្ដួចកុំឲ្យដាច់ បើរកគិតឲ្យឧស្សាហ៍ រះរកផ្ទៀតណា ឲ្យបានច្រើនក្រវើនទុក ៗ នឹងចាយឲ្យគិតក្រោយ ទោះនឹងឲ្យៗ មើលមុខ កុំឲ្យស៊ីគ្រលុក ទោះនឹងទុកឲ្យចំណាំ ៗ ផ្លូវធ្វើចំការ ឲ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ ស្លឹកគ្រៃខ្ទឹមគ្រប់ត្រី ត្រាវត្រសក់សព្វបន្លែ ៗ កុំខ្ជិលកុំប្រមូស ទៅផ្ទះគេសូមគេ គេមិនឲ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ ៗ ទោះធ្វើស្រែចំការ ឲ្យឧស្សាហ៍មើលថែទាំ កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅល្ងផង ៗ កុំឲ្យបង់កំឡាំង ទោះខែប្រាំងប្រើឲ្យដង ទឹកទៅស្រោចស្រប់ផង ឲ្យល្អលាស់មានផ្កាផ្លែ ៗ ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំត្អូញត្អែរ ខំនិងខ្យល់កុំឲ្យល្ហែ ខ្វាបតែទៀយហើយមិនធ្វើ ៗ ជាងយប់បិតឫស្ស៊ី ត្បាញជាល្អគោកពើ កុំឲ្យស្រីស្ដីលើ ឥតអំពើធ្វើលេងទៅ ៗ កុំទុកដៃទទេ ជាងទំនេរ

បោចស្មៅព្រៅ ខាងផ្ទះខាងលំនៅ ឲ្យពលកាលកើតសុខា ។ ឲ្យ
មានក្តីបារម្ភ ធ្វើស្រែកុំចោលចំការ ដឹងដែកកាំបិតព្រា ទុកឲ្យជាកុំឲ្យ
បាត់ ។ ដេកយប់ឲ្យរាំងទ្វារ ទ្រព្យជាៗ ប្រុងប្រយ័ត្ន ត្រចៀកចាំ
កុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន ។ ប្រយ័ត្នប្រយោជន៍យូរ ទោះលក់
ដូរមើលថែខ្លួន ទោះទ្រព្យរបស់ខ្លួន ឲ្យសួរកូនសួរប្រពន្ធ ។ កុំអាង
ឯងជាប្រុស ពាយរបស់មិនគិតគន់ មិនដឹងដល់ប្រពន្ធ ព្រមព្រៀង
គ្នាឥតបើថា ។ ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ ទោះទៅលេង
ឥតការ ឥតគេរកដើរឆ្ងាយជិត ។ ឲ្យប្រាប់អ្នកនៅផ្ទះ កុំរលះឥត
គំនិត គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា ។ បើទៅជា
មានភ័ព្វ ប្រសើរគាប់នោះឥតថា ប្រសិនពានពស់ខ្លា ខ្យល់ចាប់ចុក
ឥតគេសម ។ ទោះដើរមានដំណឹង ឲ្យរំពឹងគិតបារម្ភ នឹងដើរៗឲ្យ
សម យប់ព្រលប់ឲ្យមាត់ក ។ កុំស្ងៀមកុំស្ងាត់ពួន លបលាក់ខ្លួន
ខ្លាចមិនល្អ ឲ្យមើលឲ្យមាត់ក ដើរឲ្យស្មោះសោះគេថា ។ ទោះខ្លួន
ជាប៉ុន្មាន ពាក្យសន្តានវែងមុសា គេម៉ែមកអាត្មា តាមដំណឹងដំណើរ
ខុស ។ កូនអើយបាកុំធ្លោយ កុំធ្លាប់ឲ្យអាប់កេរ្តិ៍យស ធម្មតាកើតជា
ប្រុស ឲ្យរករៀនច្បាប់មាត្រា ។ លោកថាហៅឆ្កួតបី មួយឆ្កួតស្រី
មួយឆ្កួតស្រា មួយឆ្កួតល្បែងពាលា លេងបៀប៉ោផ្គុំគាត់ ។ ទាក់
មាន់ទាក់ទា ផល់ក្អាល់គ្នាបរបាញ់សត្វ អន្ទាក់ដាក់បង្កាត់ ល្បែង

អស់នោះមិនកំណើត ។ ធម្មតាប៉ោទីងបៀ មិនដែលខ្វះណាទីងកើត
មិនពុំមានកំណើត មានតែលិចលង់ខ្លួនទេ ។ ជួនកាលគេចាញ់ឯង
រៀងពល់ល្បែងតែងទឹងរ មានកាលឯងចាញ់គេ កុំទុកចិត្តថាឯងប៉ិន ។
ពីព្រឹកស្អៀកហូលជរ ល្ងាចស្អៀកសង្វះចងក្បិន ពីព្រឹកក្បែកក្បាល
បិន ល្ងាចមិនទាន់បិនដាក់ខ្នោះ ។ ជួនកាលរាំចងដើង ព្យួរខ្ពស់
ទៀងក្បាលដាំចុះ ក្អែកស៊ីងគឹងក្រញុះ រាំទារប្រាក់ឲ្យបានឆាប់ ។
មើលមុខល្អិតបអ៊ី មិនខ្មាសស្រីផ្សារឈរស្តាប់ មុខមិញដូចគេស្លាប់
មាត់ស្ងួញស្ងាញពោបដូចក្អែង ។ ស្រែកថ្ងូរអេះអូយអើយ អាចិកអើយ
អាណាក់តលែង អញរកប្រាក់ឲ្យឯង ឲ្យអាចិកស្អែកនេះបាន ។ ចិនពុ
ព្រមស្រាយមក បណ្តើរគេប្រាក់បន្ទាន់ តឹងទារទាល់តែបាន ទ្រព្យ
ឲ្យទៅទើបរាំលែង ។ អ្នកអាយអ្នកអើយកុំ គួរបោះម្កពល់តែល្បែង
កុំលកុំលូកលេង គួរឲ្យរាំងឲ្យរៀរសោះ ។ កុំឈរកុំឈប់ជិត ក្រែង
មិនអត់ចង់ក្តើកោះ កុំល្បងល្បែងនោះសោះ គួរឲ្យដោះឲ្យដើរចេញ ។
ច្បាប់នេះចាំពល់ខ្លួន ទោះបងប្អូនមិត្តសំឡាញ់ ពឹងខ្លួនឯងឲ្យចេញ
ណានាទ្រព្យគេយកទៅ ។ ឯទ្រព្យបានទៅរាំ ឯងណានាស្រាប់តែនៅ
រាំបានទ្រព្យយកទៅ ខ្លួនឯងនៅណានាស្រាប់ ។ ដល់គេមកតឹងទារ
អ្នកណានាឲ្យបានឆាប់ មិនបានគេប្រចាប់ ទៅជាខ្ញុំព្រោះណានា ។ ទោះ
បងប្អូនផ្ទះ ក្រដំពាក់គេតឹងទារ បើមានទ្រព្យជួយជា កុំណានាណាអ្នក

អាយ ៗ កូនអើយចូរចាំ ឪពុកផ្ដាំកុំបីណាយ ប្រយ័ត្នពលរូបកាយ
កុំឲ្យភ្លេចពាក្យនេះណា ៗ មួយទៀតហៅឆ្កួតស្រី គួរកុំបីសេពកាមា
វាតែងទាញអាត្មា នាំវង្វេងភ្លេចបាបបុណ្យ ៗ ភ្លេចសីលទានសូន្យ
សោះ ភ្លេចឃ្លាំងខ្លោះដល់ដីពន្ធ ភ្លេចទោសភ្លេចទាំងគុណ ភ្លេចទាំង
ការការពារសោយ ៗ បង្កើតតែទោសទុក្ខ បើបានសុខសឹងប្រែក្លាយ
បង្កើតក្ដៅក្រហាយ ឲ្យទាស់ទែងខឹងទឹងគ្នា ៗ បងទោសគុំគួន មិន
គិតខ្លួនខ្លាចមរណា មានកាលក្ឃយនឹងមា គុំធ្វើគ្នាឲ្យសោះសូន្យ ៗ
បង្កើតតែចិត្តធំ ទៅគុំនុំទឹងជីដូន ឯបងខឹងទឹងប្អូន ម្ដាយទឹងកូនគុំធ្វើគ្នា ៗ
វង្វេងគុំកាប់ម្ចាស់ ឲ្យក្ដៅណាស់កងអង្គា កើតទោសខឹងទឹងគ្នា ជាតិទុំ
ពុំត្រាសើយ ៗ មានកាលគេដាក់ឃ្នាង វាមិនរាងចាលចិត្តឡើយ
លក់ក្ន័យខ្ញុំគេហើយ មិនខ្លាចស្លាប់ដល់អាត្មា ៗ គេវាយដោតទាំងក្បាល
មិនបេះចាលចិត្តឡើយណា ភ្លេចខ្លួនសូន្យសោះសា ទឹកតែត្រង់សេព
សប្បាយ ៗ រីឯកាមកិលេស កុំប្រហែសគួរឲ្យណាយ ស្អិតណាស់
ណាអ្នកអាយ អ្នកអើយកុំគិតសង្ស័យ ៗ នេះឯងហៅឆ្កួតស្រី គួរកុំ
បីឲ្យគាល័យ ចូរចងចាំសព្វថ្ងៃ ទុកទូន្មានអង្គអាត្មា ៗ អ្នកប្រាជ្ញ
លោកនិទាន ទុកទូន្មានិកលរូបា មួយហៅឆ្កួតសុរា នោះកុំផឹកវាស្រវឹង ៗ
វានាំភ្លេចវិញ្ញាណ ភ្លេចសីលទានសោះសូន្យឈឹង ផឹកហើយមិនដែល

ទឹង នាំចិត្តនោះឲ្យធំក្រៃ ។ ឯខ្លួនឯងតូចទេ មើលទៅគេប៉ុនមេដៃ
កំឡាំងឯងស្មើរៃ មិនកោតគេតិចឡើយណា ។ ក្អេងក្អាងពាក្យកក្អែ
អ្នកពូកែបទបានស្រា មិនមានខ្លាចនរណា ស្រដីកោងរកកលឈ្លោះ ។
បញ្ចោរបញ្ចៀសផ្តាស ដេររ៉ាងរ៉ាសមិនចំណោះ នាំហេតុតែខាងឈ្លោះ
ឆ្លើយឆ្លងពាក្យឲ្យបានទាក់ ។ ប្រពន្ធឃើញឃាត់ទៅ ប្តីមិនត្រូវថាកុំ
អ្នក ឯងទឹងលោតយធាក់ ដោយចិត្តធំបទបានស្រា ។ មានកាល
ដួនស្រវឹង ពុំមានដឹងខ្លួនឡើយណា ដើរដួលដេកផ្កាប់ផ្ងារ ស្រាត
សំពត់អស់ពុំដឹង ។ គេឃើញអស់ខ្មាសក្អំ ក្មេងដៀរជុំសើចទ្រហឹង
ដេកដូចគេស្លាប់ឈឹង ក្អែរក្អួតពាសពេញទាំងខ្លួន ។ កំណើតអ្នកផឹក
ស្រា កុំអួតថាឯងទឹងទួន ផឹកហើយស្រវឹងមួន ខ្លួនខ្សត់ទេអួតថា
មាន ។ អ្នកស្លុតទៅជាកាច ឯអ្នកខ្លាចទៅជាហ៊ាន ខុសត្រូវទៅ
បំពាន បំពុលខ្លួនឲ្យបានបាប ។ នេះឯងហៅឆ្កួតស្រា ក្នុងធម៌ថា
ពៀរដេរាប អ្នកណាផឹកៈហើយបាប បង់កិត្តិយសពុំសួស្តី ។ គួរកុំសេព
សុរា នាំអាត្មាឲ្យអប្រិយ ទីងធ្លាក់ទៅអវិចី នរករង់ទុក្ខវេទនា ។ ហៃ
អស់ជនទាំងឡាយ កុំកយមាយក្នុងអគ្គា ចូរស្តាប់ច្បាប់នេះណា ទុក
ខ្នានខ្លួនសព្វថ្ងៃ ។ នេះឯងហៅឆ្កួតបី លោកស្រដីក្នុងធម៌ថ្លៃ បើ
អ្នកណាមួយនៃ ទឹកប្រាថ្នាដោយចំណង់ ។ លោកបងជាឧបមា ឲ្យ

អ្នកណាមួយផ្ចិតផ្ចង់ យកដែកដុលបោះបង់ ក្នុងភ្លើងក្រានចេះព្រាល ផ្អៅ ៗ បើកាន់ដែកដែលដុត នោះមិនមុតមិនមានក្ដៅ កាន់បាននោះទើបហៅ ចិត្តមុតមែនមិនគិតប្រាណ ៗ នោះទើបលោកឲ្យធ្វើ នូវអំពើទាំងបីបាន ដោយធម៌ពីបុរាណ លោកឧបមាដូច្នេះណា ៗ ចាត់ចែងតែងជាបទ ព្រហ្មប្រាកដកាលបិតា ប្រដៅខ្ញុំនេះណា សព្វសេចក្ដីដូច្នេះនៃ ៗ កិច្ចកាព្យពយរៀបរស ខ្ញុំនាមឈ្មោះបណ្ឌិតមៃ គិតបងជាសេចក្ដី ប្រដៅផនចប់ម៉្លេះហោង ៗ

ច្បាប់ប្រុស ចប់តែប៉ុណ្ណេះ ៗ

## បិសាចស្នេហា

(ភាគទី៦ចប់)

ក្នុងមួយរំពេចនោះ ទឹកមុខរបស់នាងក្រមុំឡើងស្វាំង ចុះទៅជាងមុនច្រើន ដោយនាងសារុនដឹងជាក់ច្បាស់ថា ឧត្តមស្រឡាញ់ខ្លួននាង ចាប់ចិត្តប្រតិព័ទ្ធចំពោះរូបនាងយ៉ាងច្រើនលើសលន់គណនា ប៉ុន្តែនាងមិនចាប់ចិត្តស្រឡាញ់គេសោះឡើយ ព្រោះនាងទៅជាប់ចិត្តស្ទុងចិត្តស្រឡាញ់លោកវ័ត្តចៅក្រមកំឡោះយ៉ាងជ្រៅជក់ខ្លួនមិនរួច តែតាមដោយពិតនោះ នាងមានចិត្តអាណិតអាសូរឧត្តមជាទីបំផុត តែខ្លួននាងមិនអាចផ្លាស់សេចក្ដីស្នេហារបស់នាងដែលជាប់នៅនឹងរូបលោកវ័ត្តឲ្យត្រឡប់មកបិតនៅលើរូបរបស់ឧត្តមបានឡើយ ! ទើបនាងនិយាយត្អូញថា :

“ពុទ្ធោអើយ ! នេះហើយជាកម្មក្រាស់របស់សារុន !” នាងនិយាយទាំងទឹកភ្នែកហូរស្រក់ជោកថ្ពាល់ទាំងសងខាង មុខគួរឲ្យអាណិតអាសូរពន់ពេក “ខ្ញុំក៏បានឃើញសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដរបស់លោកជាក់ស្ដែងហើយ ! ប៉ុន្តែៗ លោកកុំឲ្យខ្ញុំថាឡើយ” នាងឈប់ដកដង្ហើមវែងមិនដឹងជាអ្វីទៀត ហើយយកដៃទាំងពីរបិទមុខផ្ទប់នៅនឹងភ្នាក់កៅអីយ៉ាងហ័ស ; ពាក្យចុងក្រោយបង្អស់ដែលនាងសារុនពោលចេញមកនោះ ធ្វើឲ្យឧត្តមបាឡាត់កំឡោះស្ទើរតែបាត់ស្មារតី, ភ្នែកទាំងពីរមើលទៅដោយអារម្មណ៍រវើរវាយ ហើយមានពណ៌ក្រហមព្រឿងៗមកមុខគួរឲ្យសង្វេគ, ទើបឧត្តមលូកដៃទៅចាប់ដៃនាងសារុនហើយថា :

"ប្អូនសារុន ! ឱ ! ប្អូនមិនស្ដាប់ត្រចិត្តរៀបការនឹងបងសោះហើយឬ ? ឧត្តមនិយាយទាំងខ្សឹកខ្សួល ទឹកមុខឡើងសស្លាំងជាងមុនទៅទៀត មុខគួរឲ្យអាសូរករុណា ដល់ប្រុសក់ឡោះនោះពន់ពេក ។

"ចាះ, ទេលោក" - នាងងើបឡើងហើយនិយាយថា "មិនមែនដូច្នោះទេ លោកឧត្តម" នាងសារុនឈប់ដកដង្ហើមធំមួយដងហើយថា "លោកអើយ ! ខ្ញុំ-ខ្ញុំ-មាន-មានគូដណ្ដឹងហើយ ! ហ្ហើយកុំឲ្យខ្ញុំថាឡើយ" ។

"ប្អូន ! ឧត្តមតាំងចិត្តនឹងសួរបញ្ជាក់ម្ដងទៀតតែហាមាត់ច្រេហ ។ ទើបនាងសារុនឆ្លើយតបយាំងខ្សឹកខ្សួលថា "ខ្ញុំផុងចិត្តគិតទៅលើលោកត្រូវបេទៅហើយ" ថាហើយកតេតម្មូមាឡើងទៅលើផ្ទះបាត់ទៅ ។ ខាងលោកឧត្តមឈរមើលស្រទ្បាំងកាំង កើតសេចក្ដីទោមនស្សត្រូវចិត្តស្ទើរសន្លប់នៅទីនោះឯង ។

ប៉ុង ! ប៉ុង ! - សូរកាំភ្លើងលាន់ឮឡើង ក្រោយដែលនាងសារុនតេឡើងទៅដល់លើផ្ទះ ឯកឯកាយរបស់ប៉ាទ្បាក់ក់ឡោះនោះក៏ដួលស្រែសនៅទីនោះឯង ហើយពោលពាក្យចុងក្រោយបង្អស់ថា:

"ប្អូន — ប្អូនសារុន ! បង — សូមលា — ស៊ិនហើយ, ជាតិ — ជាតិក្រោយ - សុំឲ្យបានជួបគ្នា . . . . អួយ ! — អួយ ! — មច្ចុរាជ . . . ." ឧត្តមមិនប្រឹងនិយាយតទៅទៀត តែហាមាត់មិនរួច ព្រោះស្ដេចមច្ចុរាជចាប់អូសយកជីវិតឧត្តមបាត់ទៅហើយ ។ "តុះង្ហោ ! តុះង្ហោ ! អនិច្ចា

សង្ខារទាំងឡាយមិនទៀងឡើយ! ក្មេងស្លាប់ទៅមុនចាស់មានគរគោក ដូចរូបឧត្តមបុរសកំឡោះ មានអាយុត្រឹម ២៤ ឆ្នាំប៉ុណ្ណោះបានដល់អនិច្ចកម្មទៅ ព្រោះតែសេចក្ដីស្នេហា តោងមកលះបង់ជីវិតខ្លួនគ្មានអាឡោះអាល័យដោយដៃខ្លួនឯង ៗ មួយវិញទៀត ព្រោះឧត្តមគិតឃើញថា ជីវិតសត្វលោកតែប្រាសចាកសេចក្ដីស្នេហាជាជីវិតឥតខ្លឹមសារ ព្រោះមនុស្សលោកដែលមានជីវិតស្រស់បស់រីករាយសប្បាយនៅក្នុងលោកនេះបាន ដោយសារតែសេចក្ដីស្នេហាជាបច្ច័យ . . . ៗ

ក្នុងខណៈនោះ បណ្ដាមនុស្សម្នា ក៏ផ្អើលឆោឡោឡើងមកហោមរោមនៅជុំវិញពងកាយឧត្តម, តែលោកឧកញ៉ាបរិបូរសម្បត្តិចាត់បម្រើឲ្យយករថយន្តទៅទទួលលោកឧកញ៉ាពជបម្រើនឹងលោកស្រីឲ្យមកជាប្រញាប់ ហើយហាមមិនឲ្យនរណាទៅប៉ះពាល់ពងកាយរបស់ឧត្តមឡើយ ៗ លោកឧកញ៉ានឹងលោកស្រីជាមាតាបិតាមកដល់ ក៏យំសោកខ្សឹកខ្សួល បោកខ្លួនបោកប្រាណ ដោយកូនសំឡាញ់តែមួយមកបោះបង់ជីវិតកំពុងពេញកំឡោះស្លូតដូច្នោះ មុខគួរឲ្យសោកស្ដាយណាស់ លោកឧកញ៉ាម្ចាស់ផ្ទះព្រមទាំងបុត្រការិយា នាងសារី-នាងសារុន សឹងនាំគ្នាយំសោកដោយសេចក្ដីអាឡោះអាល័យទាំងអស់គ្នា ក្នុងចំណោមអ្នកយំសោកនោះ នាងសារុនមានសេចក្ដីអាល័យនឹងយំសោកច្រើនជាងគេ ព្រោះឧត្តមបាត់បង់ជីវិតទៅនោះ ដោយសារខ្លួននាងឯងជាដើមហេតុ នាងតោងបាត់បង់

សង្សារកំសត់ស្មោះត្រង់បំផុតតែមួយ  ក្នុងលោកនេះនឹងរកបុរសដទៃឲ្យមានសេចក្ដីស្មោះត្រង់នឹងនាងស្មើនឹងឧត្តមពុំមានឡើយ ។ លុះស្បើយសេចក្ដីសៅសោកគ្រាន់បើបន្តិចហើយ ទើបលោកឧកញ៉ាម្ចាស់ផ្ទះនឹងមាតាបិតានាំគ្នាពិនិត្យមើលសពរបស់ឧត្តម  ឃើញមានកាំភ្លើងដៃនៅនឹងខ្លួនសព ដែលមាតាបិតាស្គាល់ច្បាស់ថាជាកាំភ្លើងគូដៃរបស់ឧត្តម ក្រៅពីនោះឃើញមានកូនសំបុត្រមួយចំពោះដល់នាងសារុន មានសេចក្ដីខ្លីៗថា

ប្អូនសារុន!

កូនសំបុត្រនេះ ជាសាក្សី សំដែងសេចក្ដីស្នេហាដ៏បរិសុទ្ធរបស់បង! មុនប្អូនបានឃើញសំបុត្រនេះ បងស្មានថាប្រហែលជាបងបែកឋានទៅចាំជួបប្អូននៅលោកខាងមុខរួចទៅហើយ!

ឱ! សារុន មាសព្រលឹងក្រៃលែងជាងជីវិតរបស់បង ជីវិតបងសព្វ-ថ្ងៃជាជីវិតក្រៀមក្រោះឥតសប្បាយរីករាយបន្តិច! សូមប្អូននៅឲ្យបានសេចក្ដីសុខក្សេមក្សាន្តណាះប្អូនណា! ។

លាសិនហើយៗ! ប្អូនសំឡាញ់ស្មើជីវិត ជាតិក្រោយសឹមជួបគ្នា ហើយសុំឲ្យបានរួមរសស្នេហាកុំបីឃ្លាត!

សួស្ដី!

ប្អូនស្រីសំឡាញ់បង!

ឧត្តម

តអំពីនោះ លោកឧកញ៉ាជាមាតាបិតានិងលោកឧកញ៉ាជាម្ចាស់ផ្ទះ ក៏ចាត់ចែងធ្វើបុណ្យឧទ្ទិសផលដល់អ្នកដែលបានទៅតាមទំនៀមៗ ឯរឿងរ៉ាវនៃហេតុអត្តវិនិបាតកម្មនេះ ក៏ស្ងប់ស្ងាត់ត្រឹមណោះឯង ព្រោះត្រកូលទាំងពីរធ្លាប់មានមេត្រីរាប់អានគ្នា ដោយសេចក្ដីស្មោះត្រង់តាំងពីដើមរៀងៗមក ឥតមានមោះមៃមន្ទិលអ្វីដល់គិតឡើយ ៗ

✡

✡ ✡

អំណើះកាលជាលំដាប់មក លោកវ័ត្តឬលោកចៅក្រមវ័ត្តតែងឆ្លៀតឱកាសទៅលេងផ្ទះបរិបូរសម្បត្តិ ព្រោះតែមានសេចក្ដីស្និទ្ធស្នាលនឹងលោកឧកញ៉ាជាម្ចាស់ផ្ទះព្រមទាំងកុមារីទាំងគូ គឺនាងសារីនិងនាងសារុន ៗ តាមៈដោយពិតនោះ! លោកវ័ត្តចាប់ចិត្តស្នេហាទាំងបងទាំងប្អូន កងចិត្តមិនដឹងជាបោលណាយកណា ប៉ុន្តែគំនិតគិតបងចង់បានទាំងពីរ, មកដល់គ្រាណេះខួរក្បាលលោកវ័ត្តកើតចលាចលកន្ទុះពមិនដាច់ស្រេច លុះគិតយូរៗទៅ ក៏ដាច់ចិត្តជះស្រឡះថា "បើបានបងហើយ តើប្អូនទីងទៅណា!" ៗ

កាលកន្លងទៅមិនយូរប៉ុន្មាន មានកំណត់រៀបមង្គលការរវាងលោកចៅក្រមវ័ត្តធ្វើការនៅសាលាវិនិច្ឆ័យជាគូនឹងនាងក្រមុំសារី ធីតារបស់ឧកញ៉ាបរិបូរសម្បត្តិ ៗ លុះបានឫក្សពារពេលល្អ ទើបលោកឧកញ៉ាជាម្ចាស់ផ្ទះក៏ឲ្យចាត់ចែងប្រដាប់ប្រដាគេហដ្ឋានរបស់លោកដោយខ្ពង់

ជ័យទង់ជាតិច្រើនជាអនេក ហើយឲ្យចងផ្លូវផ្កានានាតាមបង្អួចនិងទ្វារ សឹងមានក្លិនក្រអូបឈ្ងុយឈ្ងប់ផ្សព្វផ្សាយទូទៅទាំងគ្រឹហាស្ថាន, បណ្ដាភ្ញៀវដែលមានសំបុត្រអញ្ជើញមកលៀងភោជនាហារ ក៏បានមកជួបជុំមិនខ្វះខាត, ធ្វើឲ្យលោកឧកញ៉ាជាម្ចាស់ផ្ទះមានសេចក្ដីសប្បាយរីករាយក្នុងចិត្តក្រៃពេក; លុះដល់វេលារាត្រី ភ្លើងអគ្គិសនីអំពូលភ្លឺពេញទាំងបរិវេណផ្ទះសឹងមានពណ៌ខៀវ-ស-ក្រហម-លឿង-បៃតងគ្រប់បែបគ្រប់យ៉ាង មានពន្លឺភ្លឺព្រោងព្រាត សឹងល្អមើលជាចំឡែកនៅតាមមែកព្រឹក្សានានា មុខគួរឲ្យមានតម្រេកត្រេកត្រអាលដល់បណ្ដាភ្ញៀវដែលបានមកជួបជុំនៅពេលនោះទាំងអស់គ្នា ៗ

ក្នុងវេលារាត្រីនោះព្រះចន្ទរះឡើងពេញដួងបាំងពន្លឺរស្មីមកពាសពេញផ្ទៃផែនដី ហាក់ដូចជួយបំពេញសេចក្ដីសុខក្សេមក្សាន្តដល់ក្រមុំកំឡោះទាំងគូ ដែលកំពុងប្រលែងគ្នាលេងក្នុងសួនច្បារក្រោយគេហដ្ឋាន ៗ អាកាសសប្បាយរីករាយដែលប្រកបដោយកិត្តិយសដ៏ថ្កុំថ្កើងនៃពិធីមង្គលការដ៏ឧឡារិកនោះ នាំសំរើបចិត្តរបស់ក្រមុំកំឡោះទាំងឡាយឲ្យនឹកចង់រៀបមង្គលការរៀងៗគ្នា ៗ បណ្ដាជនប្រុស-ស្រី-ក្មេងចាស់-ពោះម៉ាយ-មេម៉ាយសឹងមានសេចក្ដីរីករាយក្សេមក្សាន្តជូនពរសព្វសាធុការដល់ក្រមុំកំឡោះទាំងគូព្វសួរសព្វសាទរ; ចំណែកខាងនាងក្រមុំសារុនជាប្អូនក៏សំដែងទឹកមុខញញឹមឲ្យពរសព្វសាធុការដូចអ្នកផងដែរ

ប៉ុន្តែពាក្យក្នុងទ្រូងនាងក្ដៅក្រហល់ក្រហាយស្ទើរតែឆេះជាភ្លើង តែឥតមានណាមួយដឹងដល់ចេះដូចរបស់នាងឡើយ ក្នុងចិត្តរបស់នាងស្រពោនស្រពាប់ស្លុតក្រៀម ព្រោះសេចក្ដីអាម៉ាស់ស្រអាប់ចិត្តយ៉ាងក្រៃលែង ទើបនាងកើតចិត្តធុញទ្រាន់នឿយណាយនឹងមនុស្សលោកនេះជាទីបំផុត ចង់គេចចេញចាកលោកនេះឲ្យផុតស្រឡះ ព្រោះពិភពលោកដ៏ធំទូលាយនេះ ក្លាយទៅជាទីចង្អៀតចង្អល់ចិត្តឥតមានសុខកាយសប្បាយចិត្តបន្តិចឡើយ ។

ទើបនាងក្រមុំសារុនកេទ្ទុការសដកខ្លួនចេញចាកប្រជុំជនហើយចូលទៅកាន់បន្ទប់នាងអង្គុយសោយអារម្មណ៍ក្រៀមក្រំតែម្នាក់ឯង នាងដាក់ត្លុកអង្គុយលើកៅអីក្បែរបង្អួចចំហរយកខ្យល់អាកាស តែនាងមិនបើកភ្លើងទេ ទុកឲ្យពន្លឺដួងព្រះចន្ទចាំងចូលមកតាមបង្អួច ឯខ្លួននាងក៏អង្គុយមើលរស្មីនៃដួងចន្ទយ៉ាងស្រងូតស្រងាត់ ។ ក្នុងខណៈនោះព្រះចន្ទ្រាហាក់ដូចមានចិត្តលំអៀងចូលគំនិតនឹងនាងសារីជាបងរបស់នាង ព្រោះយប់នោះថ្ងៃអោយស្រឡះ ពន្លឺព្រះចន្ទភ្លឺច្បាស់ត្រចះត្រចង់ដែលនាំឲ្យក្រមុំកំលោះទើបរៀបការថ្មី មានសេចក្ដីស្នេហាដល់គ្នានឹងគ្នាកាន់តែខ្លាំងឡើង, ប៉ុន្តែជារឿងផ្ទាស់ចិត្តរបស់នាងក្រមុំសារុនយ៉ាងខ្លាំង ព្រោះក្នុងវេលានោះ នាងដេកក៏មិនសុខ អង្គុយក៏មិនស្រួល ហាក់ដូចជាក្រហល់ក្រហាយអន្ទះអន្ទែង, ទើបនាងស្ទុះក្រោកទៅឈរនៅមាត់បង្អួចក្រឡេកមើលទៅសព្វទិសានុទិស ដើម្បីដកដង្ហើមឲ្យបានធូរទ្រូងបន្តិច

ប៉ុន្តែក្នុងខណៈដែលក្រឡេកមើលចំទៅស្រាប់តែភ្ញាក់ខ្លួនព្រឺតមានសេចក្តីភិតភ័យតក្កមា ព្រោះបានឃើញរូបភាពមនុស្សស្លុង ៗ លេចចេញពីស៊ុមទ្រមគុម្ពឈើមួយក្នុងសួនច្បារ ជារូបបុរសក់ឡោះដូចជាខ្មោចដែលទើបស្លាប់ទៅ ហើយបេអណ្តែតឡើងមកសំដៅមាត់ទ្វារបង្អួចដែលនាងនៅ ពាំងកាយរបស់នាងក្រមុំក៏ញាប់ញ័ររន្ធត់ស្ទើរលេតស្មារតី ចង់ស្រែកហៅគេឲ្យមកជួយក៏ហាមាត់មិនរួច ទឹងឈានជើងរត់ក៏រត់មិនកើត ព្រោះរឹងគាំងទាំងអស់ នាងឈរស្រឡាំងកាំងមួយស្របក់ ទើបរូបកងបិសាចនោះអណ្តែតឡើងមកចូលតាមចន្លោះបង្អួចមកជិតខ្លួននាងក្រមុំ។ យកដៃទាំងពីរទាត់ច្រានយ៉ាងខ្លាំងបង់ឲ្យបិសាចនោះថយឆ្ងាយពីខ្លួននាង តែដៃទាំងពីរដែលខំច្រានទាត់ទៅនោះ ឥតសម្លួសប៉ះអ្វីឡើយ ក្រៅអំពីអាកាសទទេ, ហើយរូបបិសាចនោះក៏ឈានជើងដើរវិលងក្បាលនាងទៅអង្គុយលើកៅអីមួយដែលនៅចំពីមុខនាង ហាក់ដូចជាមនុស្សមានជីវិតវិញ្ញាណសុទ្ធសាធ ។ នាងក្រមុំសារុនក៏ងាកបែរទៅមើលរូបបិសាចនោះ ដោយកិរិយាស្ទន់ស្រឡាំងកាំងហាក់ដូចមនុស្សឥតវិញ្ញាណ នាងឃើញច្បាស់ថា រូបបិសាចនោះ គឺជារូបខ្មោចសង្សារកំសត់របស់នាងឥតល្អៀង រហូតដល់សំពត់អាវស្លៀកពាក់ទឹងទ្រង់ទ្រាយឫកពា ក៏ជាខ្មោចសុទ្ធសាធដូចជាសំលៀកបំពាក់ក្នុងថ្ងៃដែលស្លាប់ដោយឧបត្តិហេតុនោះឯង, នាងក្រមុំចាំបានជាក់លាក់ជាប់នៅនឹងភ្នែកនាង, ទើបនាងនឹកតែក្នុងចិត្តថា "មែន

ហើយ! មែនហើយ! ជារូបបិសាចឧត្តម សង្សាររបស់នាងជាប្រាកដ" ។ កន្លងមួយស្របក់នោះ បិសាចនោះក៏សន្សើមៗ ហាមាត់និយាយបន្តិចៗ; នាងស្រីក្រមុំបានឮសំដីយ៉ាងត្រជាក់ស្រែក ឮស្អួរស្រួចក្រលួចខុសពីមនុស្សធម្មតា មុខគួរឲ្យព្រឺក្បាលយ៉ាងសំបើម: សំដីបិសាចនោះថា:

"នាងសារុនអើយ! ខ្លួនខ្ញុំនេះ គឺឧត្តមសង្សារកំសត់របស់នាងៗ ចាំខ្ញុំបានទេ? ទុកជាខ្ញុំស្លាប់បាត់ទៅហើយក៏ពិតមែន ប៉ុន្តែវិញ្ញាណរបស់ខ្ញុំមិនបានស្លាប់ទៅជាមួយនឹងរាងកាយទេ ខ្ញុំនៅមានចិត្តស្រឡាញ់នាងជានិច្ចសូម្បីស្លាប់ទៅជាខ្មោចហើយក៏ដោយ, ពុទ្ធោអើយ! នាងឥតចិត្តអាណិតអាសូរដល់ខ្ញុំបន្តិចឡើយ នាងគង់បានដឹងប្រាកដហើយថាឧត្តមៈនេះជាប់ចិត្តស្នេហាលើរូបនាងត្រឹមណា? ខ្ញុំស្លាប់ទៅនេះ ដោយសារតែនាងផ្តាច់មេត្រីចិត្តដាច់ស្រឡះពីខ្ញុំ មិនព្រមរៀបការនឹងខ្ញុំសោះឡើយ ខ្ញុំនឹងទំទ្រាំទ្រជីវិតដ៏ក្រៀមក្រំមានតែទុក្ខតទៅទៀតពុំបានទេ ទើបលាលះមនុស្សលោកនេះទៅមុន, ឱ, សារុននាងអើយ ជាតិនេះមានកម្មនាំឲ្យនាងឥតចិត្តអាណិតខ្ញុំ ជាតិក្រោយសូមនាងមេត្តាខ្ញុំខ្លះផង, សារុន នាងអើយ! បែរមុខមកញញឹមឲ្យខ្ញុំធូរទ្រូងបន្តិចបំណាច់ចំណៀតមកស្រួលដល់បន្ទប់ដេករបស់នាង, ពុទ្ធោអើយ! ឧត្តមមិនចង់ឃ្លាតចេញពីខ្លួនទន្ទូននាងបន្តិចឡើយ ព្រោះឧត្តមស្រឡាញ់ប្អូនទឹកលើកជានិច្ច តែនឹងមកត្រានៅយូរដូច្នេះមិនបានទេ, សារុនអើយ ខ្ញុំសូមលាសិនហើយ.

សូមឲ្យនាងនៅជាសុខក្សេមក្សាន្តទៅចុះ!" ហើយបិសាចនោះក៏ក្រោកឡើងលើកដៃទាំងពីរដោយទំនងចង់ឱប ហើយនិយាយថា "សារុននាងអើយ ចូរនាងមកជិតខ្ញុំបន្តិចសិនពា!" ។ ឯនាងស្រីក្រមុំកាលបានស្តាប់សំដីបិសាចមុខគួរឲ្យអាណិតវេទនាដូច្នោះ នួននាងក៏ដើរចូលទៅក្រោមចាំងមិនដឹងខ្លួន មានទឹកភ្នែកហៀរហូរចេញមកសស្រាក់, កាលនាងបានចូលទៅជិតខ្លួនបិសាចនោះស្រាប់តែស្ទុះស្រឡាំងកាំងនឹកធ្ងល់ណាស់ ព្រោះរូបបិសាចដែលនៅចំពោះមុខនាងនោះបាត់ទៅមួយរំពេច ៗ នាងក្រមុំសារុននឹកស្ដាយណាស់ដែលមិនបានឲ្យសេស្នេហាដល់ឧត្តម រឿងនេះនាងនឹកក្រៀមក្រំស្ដាយក្រោយជាបំផុត ព្រោះក្នុងលោកនេះនឹងរកបុរសដទៃឲ្យមានសេចក្ដីស្នេហាស្មោះត្រង់ស្មើនឹងឧត្តមមិនមានឡើយ ថែមទាំងបំណងរបស់នាងក៏មិនបានសម្រេចដូចសេចក្ដីប្រាថ្នា ព្រោះបុរសកំឡោះជាទីគាប់ចិត្តរបស់នាង ដែលមាននាមថាចៅក្រមរត្ន ហើយនួននាងមានសង្ឃឹមថាមុខជាបានរៀនខ្ទើយរួមរសសេស្នេហាជាមួយនឹងនាងនោះ បែរជាបានទៅនាងក្រមុំសារីជាបងស្រីរបស់នាងស្រឡះ ថែមទាំងខូចបង់ប្រុសកំឡោះដែលមានចិត្តស្មោះត្រង់បំផុត ស្រឡាញ់ខ្លួននាងជាបំផុតទៅម្នាក់ទៀតផង ។

តាំងអំពីវារៈនោះរៀងមក នាងក្រមុំសារុនចាប់មានចិត្តរវើរវាយខ្វល់ខ្វាញ់សោហ្មងយ៉ាងក្រៃលែង រាងកាយក៏ស្គាំងស្គមស្គតស្គាំង, បិសាច

ឧត្តមដែលនាងបានឃើញក្នុងយប់នោះទៅជានិមិត្តជាប់ជិតនៅក្នុងចិត្ត
របស់នាង ជាហេតុធ្វើឱ្យចិត្តគំនិតនាងកាន់តែរាយមាយច្រើនឡើងស្ទើរ
ទៅជាឆ្កួតលលា; នៅវេលាព្រឹកមួយនោះ ចិត្តគំនិតនាងអណ្តែតអណ្តូង
រាយមាយផ្តេសផ្តាស គិតរកឧបាយបំកសព្រាត់សង្សាររបស់បងស្រី
ដើម្បីឱ្យសេចក្តីប្រាថ្នារបស់នាងបានសម្រេច, តែនាងស្វែងរកឱកាស
បះបោរពុំទាន់បាន ថែមទាំងបានឃើញសេចក្តីស្រះស្រលម្ពូលមិត្តនៃស្វាមី
ភរិយាគូនេះផងទៀត, កាលវេលាកាន់តែកន្លងទៅ, សេចក្តីស្និទ្ធស្នេហា
កាន់តែជាប់ជួនមាំមួនឡើងពីលំៗថ្ងៃ ។ អនិច្ចា! មុខគួរករុណាអាសូរ
នាងក្រមុំសាវទពន់ពេក! នាងគយគន់រកឱកាសបន្ទោរទង់បំបែកបំបាក់
សង្សាររបស់បងស្រីនាងពុំបានឡើយ, ទើបនាំឱ្យរាងកាយរបស់នាង
ក្រមុំកាន់តែក្រៀមក្រំស្គាំងស្គមថយកំឡាំង សម្បុរស្រស់ស្រាំងឥតមាន
ឈាមដក់ក្នុងខ្លួន ។

*

* *

ពិភពលោកបានវិលជុំវិញខ្លួនឯង ២៩ ជុំត្រូវជា ២៩ ថ្ងៃ, លោក
ចៅក្រមវត្តមានបង្គាប់ពីពួកការធំឱ្យចេញទៅពិនិត្យក្តីសំខាន់នៅសាលាជំ
ប៊ូនីខេត្តកំពតជាប្រញាប់ហើយអស់វេលាយូរថ្ងៃផង, ទើបលោកវត្តតោង
ចេញចោលភរិយាជាទីស្នេហាទៅតាំងទីកន្លែង មានសេចក្តីអាឡោះអា-

ល័យដល់គ្រួសារជាបំផុត ព្រោះទើបរៀបការថ្មីៗ ហើយរួមរស់ស្នេហា មិនទាន់បានពេញ ១ ខែផង, ស្រាប់តែមកព្រាត់ប្រាសនិរាសគ្នាទៅទៀត ចោលសង្សារស្រីឲ្យនៅកណ្ដោចកណ្ដែងតែម្នាក់ឯង ។

ក្នុងវេលារាត្រីមួយរំលងអធ្រាត្រហើយ, ទ្វារបន្ទប់ដេករបស់នាងសារី ភរិយារបស់លោកចៅក្រមរ័ត្ន បើមានគេចាំគន់មើលទំនងបានឃើញទ្វារ នោះសន្សឹមៗបើកចេញបន្តិចម្ដងៗដោយដៃស្ត្រីក្រមុំរាងតូចស្ដើង, ស្លៀកខ្មៅ, ពាក់ខ្មៅ, ទទូរក្រមាខ្មៅ, ឃ្លុំមុខផង, នាងនោះសន្សឹមៗលបដើរចូលទៅក្នុងបន្ទប់, ដៃម្ខាងកាន់កាំបិតស្នៀតស្លាប ចុងស្រួច កាំបិតនោះមុតជាបំផុត ។ នាងនោះដើរចូលទៅជិតគ្រែដេករបស់នាងសារី នៅវេលានោះ នាងសារីកំពុងដេកលក់យ៉ាងស៊ប់ស្ងួនឥតដឹងខ្លួន ប្រមើបន្តិចឡើយ, ថែមទាំងក្នុងអធ្រាត្រនោះស្ងាត់ជ្រៀប ឥតមាននរណាមួយក្នុងផ្ទះក្អកគ្រ-ហែមដល់តិចសោះ ។ កាលនាងនោះចូលដល់ជិតខ្លួននាងសារីហើយ ក៏សើយមុងឡើង យកដៃទាំងពីរចាប់កាំបិតលើកឡើងលើផុតក្បាលនាង បំរុងនឹងចាក់ឲ្យចំបំពង់ករបស់នាងសារីដែលកំពុងដេកលក់ស៊ប់នោះ, ស្រាប់តែមានរូបបិសាចឈ្មោះឧត្តមមកប្រាកដជាក់ស្ដែងនៅក្បែរខ្លួននាងសារី ចំពីមុខនាងសារុន ធ្វើឲ្យសារុនក្រមុំស្រីព្រឺគ្រប់រន្ធរោម ព្រឺក្បាលសំពោង: ឯរូបបិសាចនោះស្លៀកសពាក់ស កោរក្បាលខុសប្លែកពីយប់មុន ប៉ុន្តែមុខមាត់ពក់ពៅគឺឧត្តមហ្នឹងឯង ។

"នាងសារុនអើយ!" បិសាចនោះ ពោលដោយសូរសំឡេងខ្សាវៗ ល្មមតែនាងសារុនបានឮតែម្នាក់ឯង តែជាសំឡេងខ្លោចសុទ្ធៗ ឱ! សារុនអើយ! ចូរនាងកុំធ្វើអំពើអាក្រក់ដូច្នេះឡើយ នាងជាស្ត្រីមិនគួរមានចិត្តកាចសាហាវដល់ម៉្លេះទេ នាងឯងមិនមានចិត្តមេត្តាករុណា អាណិតអាសូរនាងសារ៉ាជាបងស្រីរបស់នាងសោះឡើយឬ ? អំពើនេះមិនសមគួរដល់ខ្លួននាងដល់តិចឡើយ នាងគិតសម្លាប់បងស្រីរបស់ខ្លួន ដើម្បីដណ្តើមស្វាមីរបស់គេ ? កុំ-កុំ- នាងគិតខុសច្រើនតែម្តង នាងបំផ្លាញសេចក្តីសុខរបស់បងស្រី-ផ្តាច់ផ្តិលជីវិតបងស្រី ដើម្បីសេចក្តីសុខសប្បាយរបស់ខ្លួន, ឧត្តមយល់ថា អំពើនេះខុសទាំងខាងផ្លូវលោកទាំងខាងផ្លូវធម៌, ឱ! សារុនអើយ ចូរនាងបោះកាំបិតនោះចោលទៅតាមបង្អួចទៅ, ហើយផ្លាស់គំនិតដែលគិតខុសយ៉ាងធំនេះចេញ; ខ្ញុំគោរពលាទៅសិនណា ប្អូនស្រី តែកុំភ្លេចបណ្តាំរបស់ឧត្តមដែលបានមកជួបគ្នាក្នុងគ្រានេះឲ្យសោះ ។ រូបបិសាចនោះក៏សន្សឹមៗបាត់ទៅនៅជ្រុងជើងមុងនោះឯង ។

កាលនាងក្រមុំសារុនបានស្តាប់សំដីបិសាចជាសង្គ្រោះ របស់នាងចប់ហើយ ចិត្តគំនិតនាងក៏ទន់ល្វន់ដូចក្រមួនត្រូវថ្ងៃមួយរំពេច, ដៃទាំងពីរដែលចាប់កាំបិតនោះក៏ជ្រុះរបូតទៅក្រោយខ្នងនាងទៅ ហាក់ដូចជាមិនមានសរសៃសម្រាប់យឹតយោងអវយវៈសោះឡើយ, ហើយនាងភ្ញាក់

ស្មារតីដឹងខ្លួនថានាងប្រព្រឹត្តខុសទំនងគន្លងធម៌យ៉ាងធំតែម្ដង, តែកាលនាងនឹកដល់សេចក្ដីស្នេហា នាងនឹកស្ដាយនឹកខ្នាញ់ក្នុងចិត្តជាទីបំផុត, សំឡឹងឃើញលោកដ៏ធំទូលាយនេះមិនមានប្រយោជន៍មិនមានសេចក្ដីសុខដល់នាងសោះឡើយ, មើលឃើញសុទ្ធតែទុក្ខទាំងមានរសជាតិល្វីងជូរចត់ទាំងអស់, នាងខូចបង់ប្រុសកំលោះដែលមានសត្យសុចរិតស្មោះត្រង់ជាបំផុតទៅដោយខ្លួននាងឯងទៅប៉ុនប៉ងចង់បានឈ្មោះរត្ន ដោយនាងនឹកសង្ឃឹមថានឹងបានឈ្មោះនេះមកជារបស់នាង, ប៉ុន្តែទីទេធេង; ដ្បិតឈ្មោះរត្នបែរជាទៅរៀបការនឹងបងស្រីរបស់នាងវិញ, សមដូចពាក្យគេតែងនិយាយថា "រួចទាំងត្រី រួចទាំងទន្សាយ" ដែលមានដំណាលក្នុងរឿងសុភាទន្សាយ ។ សំដីគ្រប់ម៉ាត់របស់បិសាច សុទ្ធតែចូលជ្រួតជ្រាបដល់បេះដូងរបស់នាង, ទើបអាចដាស់តឿនគំនិតគិតខុសរបស់នាងក្នុងខណៈនោះបាន ប៉ុន្តែនាងនៅតែខ្នាញ់មិនបាត់ដោយបងស្រីនាងដណ្ដើមយកឈ្មោះរត្នរបស់នាងទៅ ត្រូវតែនាងសម្លាប់បងស្រីសងសឹកដើម្បីឲ្យបានសម្រេចតាមចំណង់របស់នាង ប៉ុន្តែឥឡូវនេះនាងនឹងប្រព្រឹត្តដូច្នោះមិនបានទេ; ព្រោះជាអំពើបាបធំណាស់ សឹងត្រូវទុក្ខទោសយ៉ាងធ្ងន់ទាំងខាងគតិលោក ទាំងខាងគតិធម៌ សមដូចពាក្យបិសាចគ្រប់ប្រការ ថែមទាំងមានចិត្តអាណិតបងស្រីនាងខ្លះផង; បើដូច្នេះ ធ្វើម្ដេចខ្លួននាងនឹង

បានឈ្មោះរ័ត្នមកជាកម្មសិទ្ធិរបស់នាង? នៅទីបំផុត នាងស្រីក្រមុំសារុន គិតដាច់ស្រេចក្នុងចិត្តថា ខ្លួននាងនៅមានជីវិតរស់នៅក្នុងលោកនេះដរាបណា, នឹងមិនបានសេចក្តីសុខដរាបនោះ; បើដូច្នេះ នាងមានជីវិតរស់នៅតទៅទៀតក៏ជាការឥតប្រយោជន៍ ! គួរនាងទៅស្វែងរកសេចក្តីសុខនៅលោកខាងមុខវិញប្រសើរជាង ។ មួយទៀត នាងនឹកអរគុណបិសាចនោះជាទីបំផុត ព្រោះថាប្រសិនបើបិសាចមិនបានទៅរំលឹកដាស់តឿនស្មារតីនាងក្នុងខណៈនោះទេ, មុខជានាងភ្លាត់បំ-ណាច់ធ្វើឃាតកម្មបងស្រីនាងជាប្រាកដពុំខាន, ម្ល៉េះសមកើតហេតុធំទៅថ្ងៃក្រោយ, ឯបំណងរបស់នាងបានសម្រេចឬមិនបានសម្រេចក៏នឹងប្រកាន់យកជាការទៀងទាត់ពុំបានដែរ ។ ឥឡូវនេះនាងក្រមុំ មានស្មារតីភ្លឺច្បាស់យល់ការខុសត្រូវគ្រប់ប្រការ ទើបនាងគិតឃើញថាបុរសកំឡោះឈ្មោះឧត្តមជាប្រុសឯកក្នុងលោកនេះ ដែលមានចិត្តស្នេហាស្មោះត្រង់បំផុត, ស៊ូលះបង់ជីវិតខ្លួន ដើម្បីជាសាក្សីនៃសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ; សូម្បីស្លាប់ទៅជាខ្មោចបិសាចហើយក៏នៅតាមមកសំដែងសេចក្តីស្នេហា ថែមទាំងជួយទំនុកបំរុងខ្លួននាងឲ្យបានរួចរួតអំពីអំពើបាបយ៉ាងធំទៀតផង, បើដូច្នេះគួរតែខ្លួននាងក្រមុំសម្រួលកាយ សម្រួលចិត្តទៅតាមបំណងរបស់គេទើបត្រូវ, មិនគួរខ្លួននាងរឹងទទឹងនឹងមេត្រី

ចិត្តដ៏បរិសុទ្ធរបស់គេឡើយ , គួរនួននាងទៅតាមបិសាចឈ្មោះ ឧត្តម ដើម្បីរួមរសស្នេហាទីសុខទុក្ខជាមួយគ្នា នៅនាលោកខាងមុខ ក្នុងវេលាគ្រាឥឡូវនេះចុះ ។ នាងស្រីក្រមុំសារុនគិតស្រេច ខុនរើសកាំបិតដ៏មុតស្រួចនោះមកមួយរំពេច ហើយចាប់កាំបិតដោយដៃទាំងពីរ ហើយចាក់ចំចុងដង្ហើមរបស់នាងឯង ដោយពេញទំហឹងដៃ, ទើបកងកាយដ៏តូចស្តើងរបស់នួននាងក្រមុំ ក៏ដួលស្រួសហូរឈាមប្រាលពាសពេញបន្ទប់ដេករបស់បងស្រីនោះឯង ដាច់ខ្យល់ស្លាប់មួយរំពេច ឥតមានសូរស្រែកបន្តិចឡើយ ។

អនិច្ចា! ជីវិតស្ត្រីក្រមុំព្រហ្មចារិណី ជាបុត្រីរបស់លោកឧកញ៉ាបរិបូរសម្បត្តិ បានក្សិណក្ស័យហើយ, មុខគួរឲ្យអាណោចអធមជាទីបំផុត, ដោយឧប្បត្តិហេតុចំឡែកណាស់ជាហេតុកម្មអស្ចារ្យ; គ្មាននរណាមួយដឹងរឿងរ៉ាវឬមានមោះមែមន្ទិលសង្ស័យឡើយ; មើលទៅហាក់ដូចជារឿងស្ងាត់កំបាំងជ្រាលជ្រៅណាស់ ប៉ុន្តែពាក្យចចាមអារ៉ាមច្រើនធ្លាក់ទៅលើនាងសារីដែលជាបងស្រី ព្រោះស្លាប់នៅក្នុងបន្ទប់របស់នាង, ប៉ុន្តែស្ត្រីបងប្អូនទាំងពីរនាក់ឥតមានរឿងទាស់ទែងគ្នាបន្តិចបន្តួចសោះ, បណ្តាមនុស្សម្នាទាំងលោកឧកញ៉ាជាមាតាបិតា ក៏គ្មាននរណាមួយមានរង្កៀសក្នុងចិត្តដល់តិចឡើយ ។ ហើយលោកឧកញ៉ាជាម្ចាស់ផ្ទះបានទោរសព្ទ

ទៅប្រាប់លោកចៅក្រមក្នុងខែត្រកំពត ថានាងសារុនមានគ្រោះថ្នាក់ តែកុំឲ្យចៅក្រមរ័ត្នព្រួយបារម្ភ ថ្ងៃក្រោយនឹងបានដឹងរឿងសព្វគ្រប់ ៗ លោកចៅក្រមរ័ត្នទោរសព្ទសួរថា គ្រោះថ្នាក់ដូចម្ដេច ? លោកឧកញ៉ាឆ្លើយថា បន្តិចបន្តួចទេ កុំព្រួយអី ៗ ចំណែកខាងរាជការរក្សាទឹកដីក៏បាត់ការស៊ើបពិនិត្យឃាតកកម្មនោះយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែរាវរកហេតុពិតមិនបានឡើយ ទាំងកាំបិតស្នៀតដែលប្រើប្រហារជីវិតរបស់នាងក្រមុំនោះ ក៏គ្មាននរណាដឹងថាជារបស់នរណា គ្មាននរណាដែលបានឃើញសោះ ៗ

*

* *

យប់ថ្ងៃកន្លងទៅយ៉ាងស្រួកទន់ដូចជាគ្រឿងចក្រ សារព័ត៌មានបានចុះផ្សាយរឿងនេះយ៉ាងអឹកធឹក ហើយផ្សាយទៅគ្រប់ខែត្រខណ្ឌក្នុងកម្ពុជរដ្ឋ ៗ នៅខែត្រកំពត សារព័ត៌មានក៏ផ្សាយទៅដល់សាលាដំបូងមុនបង្អស់ ឯលោកចៅក្រមរ័ត្នក៏បានចាប់យកកាសែតលើកឡើងមើលភ្លាម ស្រាប់តែភ្ញាក់ខ្លួនព្រើត ដោយលោកបានចោលភ្នែកក្រឡេកទៅឃើញចំណងជើងមួយអក្សរធំៗ:

# ឃាតកកម្មចំឡែក

## នៅគេហដ្ឋានបរិបូរសម្បត្តិ

កាលពីថ្ងៃ ២ មេ ឆ្នាំនេះ - នៅគេហដ្ឋានបរិបូរសម្បត្តិ ឃុំលេខ ៥ ក្រុងភ្នំពេញ មានឃាតកកម្មស្ត្រីក្រមុំរូបឆោមស្រស់បស់ម្នាក់ អាយុ ១៧ ឆ្នាំ ជាបុត្រីលោកឧកញ៉ាបរិបូរសម្បត្តិឈ្មោះនាងសារុន ។

ក្នុងវេលាយប់រំលងអធ្រាត្រហើយ នាងក្រមុំនោះដេកនៅក្នុងបន្ទប់ដេករបស់ខ្លួនជាប់នឹងបន្ទប់មាតាបិតា ទាំងមាតាបិតានិងមនុស្សក្នុងផ្ទះក៏បានឃើញទាំងអស់គ្នា ប៉ុន្តែនាងត្រឡប់ជាទៅដេកស្លាប់ក្នុងបន្ទប់របស់បងស្រីដែលនៅដាច់ដោយឡែកគ្មាននរណាមួយដឹងដើមហេតុឬមានចម្ងល់សង្ស័យដល់តិចឡើយ ។

នាងក្រមុំសារុននេះទទួលអនិច្ចកម្មដោយអំណាចកាំបិតស្នៀតមួយមានចុងស្រួចមុតចាក់ចំចុងដង្ហើម ដេកស្តូកស្តឹងស្លាប់ក្បែរគ្រែដេករបស់បងស្រី ។ ក្នុងខណៈដែលយើងបានទទួលដំណឹងនេះ មិនទាន់ដឹងជាក់ច្បាស់ថា នាងស្លាប់ដោយដៃរបស់អ្នកដទៃឬដោយដៃរបស់ខ្លួនឯង,ប្រសិន

បើនាងធ្វើអត្តវិនិបាតកម្មខ្លួនឯងទេ ម្ដេចក៏មកដេកស្លាប់ក្នុងបន្ទប់របស់បងស្រីទៅវិញ ? នឹងថានាងស្លាប់ដោយដៃរបស់បងស្រីក៏មិនឃើញមានទំនងសោះ ព្រោះស្ត្រីទាំងគូនេះមិនដែលមានរឿងទាស់ទែងខ្វែងគំនិតគ្នាផល់តិចឡើយ ចុះហេតុអ្វីក៏នាងមកស្លាប់ក្នុងបន្ទប់របស់បងស្រី ? រឿងនេះស្មាត់កំបាំងពន់ពេក ស្ទើរតែហួសវិស័យនឹងរាវរកឲ្យឃើញសេចក្ដីពិត សព្វថ្ងៃនេះពជការរក្សាទឹកដីកំពុងស៊ើបពិនិត្យរកដើមហេតុយ៉ាងម៉ឺងម៉ាត់; យើងមានសេចក្ដីសង្ឃឹមថាពជការ នឹងស៊ើបរកសេចក្ដីពិតឲ្យឃើញជាក់ស្ដែងនៅថ្ងៃក្រោយជាប្រាកដ ៕

កាលលោកពៅក្រមរ័ត្នអានដំណឹងចំឡែកនេះចប់, កាសែតក៏ជ្រុះរបូតធ្លាក់ពីដៃមិនដឹងខ្លួន ដោយលោកមានចិត្តអាឡោះអាល័យស្ដាយនាងសារុនយ៉ាងក្រៃលែង, ថែមទាំងមានព្រួយបារម្ភលើសលុប, ដ្បិតនាងទៅដេកស្លាប់ក្នុងបន្ទប់ដេករបស់ភរិយាខ្លួនក្រែងត្រូវជាប់ចោទយ៉ាងមាំទៅលើរូបភរិយា ៗ ក្នុងវេលារាត្រីនោះ លោករ័ត្នកើតទុក្ខទោមនស្សសៅសោក

ក្រៀមក្រំជាពន្លឹក ឃើញសុទ្ធតែជាគ្រោះកាចទាំងអស់, ម្ល៉ោះហើយគង់យប់នោះលោកចៅក្រមរ័ត្នដេកមិនលក់ អន្ទះអន្ទែងក្នុងខ្លួនយ៉ាងចម្លែក, តាំងចិត្តថា ដល់ព្រឹកឡើងនឹងសុំច្បាប់មកក្រុងភ្នំពេញ ដើម្បីស៊ើបសួររឿងរ៉ាវនោះ ។

នាឡិកាក្នុងផ្ទះវាយឮសូរម៉ឹងៗ បួនដង លោកចៅក្រមរ័ត្ននៅដេករសាប់រសល់មិនទាន់លក់នៅឡើយទេ ស្រាប់តែឮសំឡេងឆ្មារស្រួចមកតាមចន្លោះបង្អួចក្បែរដំណេក ទើបលោកក្រោកឡើងអង្គុយក្រឡេកមើលទៅតាមចន្លោះបង្អួច ស្រាប់តែឃើញរូបរាងស្ត្រីក្រមុំម្នាក់ស្លៀកខ្មៅពាក់ខ្មៅសក់រសាយប៉ប្រះស្មា រាងរៅដូចនាងសារុនប្អូនថ្លៃសុទ្ធសាធ; ស្ត្រីនោះកាន់តែអណ្តែតជិតមកៗ ហើយហាមាត់និយាយឮសូរគ្រលួចជាសំឡេងខ្មោចថា:

“អ្នកបងរ័ត្ន អ្នកបងកំពុងធ្វើអីនៅនេះ? លោករ័ត្នភ្ញាក់ព្រើត ព្រឺក្បាលសំពោង ក្អែកមើលទៅចំរាងស្ត្រីក្រមុំនោះមិនប៉ប្រែច ចាំបានជាក់ច្បាស់ថាជារូបនាងសារុនដែលទើបទទួលអនិច្ចកម្មទៅកាលពីប៉ុន្មានថ្ងៃមុននេះ ស្រាប់តែលាន់វាចាដោយមិនដឹងខ្លួនថា

“ឱ! ប្អូនសារុន ឬ?

“ អ្នកបងនៅចាំខ្ញុំបានឬ ? ពុទ្ធោ! ពុទ្ធោអើយ អ្នកបងមិនដឹងទេឬដែលសារុនស្លាប់តើស្លាប់ដោយហេតុអ្វី ? អ្នកបង! អ្នកបងចាំស្តាប់ឲ្យ

ប្រាសំណាក់: គឺតាំងពីថ្ងៃដែលខ្ញុំបានជួបនឹងអ្នកបងនៅថ្ងៃដែលកើតឧប្បត្តិ-ហេតុដោយចក្រយានយន្តនោះ ចិត្តគំនិតស្នេហ៍ជាប់នៅក្នុងចំណងស្នេហា ដកខ្លួនមិនរួចតែម្តង, ឱ! អ្នកបងអើយ! ថ្ងៃនោះហើយដែលព្រះកាមទេព ជាម្ចាស់ទ្រង់ផ្តែងសរផ្កាមកត្រូវចំបេះដូងរបស់ខ្ញុំ, ធ្វើឲ្យខ្ញុំផុងចិត្តស្រ-ឡាញ់អ្នកបងយ៉ាងខ្លាំងបំផុត តែចំណែកខាងអ្នកបងមិនសំដែងសេចក្តី ស្នេហាតបឡើយ ថែមទាំងភ្លាន់រៀបការនឹងអ្នកបងសារីទៅទៀត, ទើប ធ្វើឲ្យខ្ញុំកាន់តែកើតទុក្ខក្រៀមក្រំយ៉ាងលើសលន់គណនា ពុំទ្រាំ នឿយណាយនឹងមនុស្សលោកនេះជាទីបំផុត ទើបខ្ញុំប្រហារជីវិតខ្លួនឯង ដោយកាំបិតស្នៀត ហើយខ្ញុំក៏ស្លាប់-ស្លាប់ព្រោះតែស្នេហាលើរូបអ្នក បង; ឱ ! អ្នកបងអើយ ! លាក់ចាំងក្ដី, កាំបិតស្នៀតនោះហើយ ដែលខ្ញុំកាន់ចូលទៅក្នុងបន្ទប់បងសារីភរិយារបស់អ្នកបង ប៉ងនឹង សម្លាប់បងស្រី ដោយអំណាចប្រចណ្ឌទង់ស្នេហាដ៏ងងឹតមុខបំផុត ប៉ុន្តែគាប់ជួនជាបិសាចរុក្ខសង្ក្រាក់សត់របស់ខ្ញុំបានទៅប្រាកដជាក់ស្តែង ខ្លួនប្រដៅក្នុងពេលនោះ, ទើបខ្ញុំបានស្មារតីឡើង ហើយយកកាំបិត នោះប្រហារជីវិតខ្លួនឯងវិញ; ឱ ! អ្នកបង ! ឥឡូវខ្ញុំលែងស្រឡាញ់ អ្នកបងហើយ ខ្ញុំបានបំភ្លេចរឿងរ៉ាវទាំងនោះអស់ហើយ សូមឲ្យអ្នក បងរួមនឹងអ្នកបងសារីប្រកបដោយសេចក្តីសុខសប្បាយតរៀងៗទៅចុះ! ៗ

មួយវិញទៀត ដើម្បីដោះសេចក្តីសង្ស័យរបស់មនុស្សលោកឲ្យបានជ្រះ

ស្រឡះ, កុំឲ្យគេមានសេចក្ដីងឿងឆ្ងល់តទៅទៀត សូមឲ្យអ្នកបងជ្រាបថា បុរសកំឡោះដែលឈ្មោះ ឧត្ដម ធ្វើអត្តវិនិបាតកម្មខ្លួនឯងនៅក្រោយគេហដ្ឋានលោកឪពុកក្នុងសួនច្បារនោះ, ព្រោះតែគេចាប់ចិត្តស្នេហាយ៉ាងខ្លាំងលើរូបខ្ញុំ តែខ្ញុំមិនព្រមស្រឡាញ់មិនព្រមរៀបការនឹងគេ; ទើបគេសម្លាប់ខ្លួនគេបង់ទៅ ដើម្បីប្រកាសឲ្យឃើញសេចក្ដីស្នេហាដ៏បរិសុទ្ធរបស់គេមកលើរូបខ្ញុំ; ឥឡូវនេះខ្លួនខ្ញុំនឹងគេបានជួបជុំមូលមិត្រគ្នាហើយ! ពិតមែនតែយើងទាំងពីរនាក់មិនបានរួមរស់ស្នេហាជាមួយគ្នានៅនាស្ថានមនុស្សលោកនេះ ប៉ុន្តែនៅនាលោកបិសាចខាងនាយឯណោះ រសជាតិនៃសេចក្ដីស្នេហាក៏មិនចាញ់ប្រៀបមនុស្សលោកនេះប៉ុន្មានទេ; ណ្ហើយ, អ្នកបង ខ្ញុំសុំលាសិនហើយ!” ។ ហើយរូបបិសាចនាងសារុនក៏បាត់ពីទីនោះទៅមួយរំពេច; លោកចៅក្រមវ័ត្តក៏អង្គុយស្រឡាំងកាំងនៅទីនោះមួយស្របក់ធំ ទើបភ្ញាក់ខ្លួនមានសតិសម្បជញ្ញៈឡើង ។ ដោយសេចក្ដីសារស័ព្ទប្រាប់រឿងរ៉ាវសព្វគ្រប់របស់បិសាចនាងសារុននោះហើយ បានជាគេអាចចងក្រងរឿងរ៉ាវនេះបានសម្រេច ឲ្យឈ្មោះថា “រឿងបិសាចស្នេហា” ។

ចប់រឿងបិសាចស្នេហាតែប៉ុណ្ណោះ ។

# កុម្ភជាតក

(តមកនិងចប់)

ពួកអាយុត្តកបុរសនាំយកសេចក្តីទៅក្រាបបង្គំទូល ព្រះមហាក្សត្រថា: "ឆ្មាំទាំងឡាយផឹកសុរាពុលស្លាប់អស់ទៅហើយ" ព្រះរាជាក៏ទ្រង់ព្រះពិរោធឡើងថា: "ពួកទាំងនេះជាអ្នកធ្វើថ្នាំពុលទេតើ" ហើយទ្រង់បង្គាប់ឲ្យកាត់ក្បាលជនទាំងពីរនាក់ ៗ ផឹកសុរាហើយក៏ស្រែកថា: "បពិត្រព្រះសម្មតិទេព ទឹកឆ្ងាញ់ៗ" ដូច្នេះ ដរាបតែស្លាប់ទៅទើបបាត់មាត់ ៗ ព្រះរាជាទ្រង់បង្គាប់ឲ្យសម្លាប់អ្នកទាំងពីរនោះហើយ ឲ្យរំលាយទាំងឆ្នុកទីន[១] ថែមទៀត ៗ លុះផល់សុរាសាបហើយ ឆ្មាំទាំងឡាយក៏ក្រោកឡើងលេងបាក់កញ្ចែងក្អៀវក្អា ទើបពួកអាយុត្តកបុរសនាំយកសេចក្តីទៅក្រាបបង្គំទូលព្រះរាជា ៗ ទ្រង់ព្រះចិន្តនាការថា: "បើទឹកនោះជាទឹកពុល សមជាឆ្មាំទាំងនោះស្លាប់ ទឹកនោះមានរសឆ្ងាញ់ពិតមែនទេដឹង អញនឹងផឹកលងមើលអេះ" ហើយទ្រង់បង្គាប់ឲ្យរាជសេវកាមាត្យទាំងឡាយរៀបចំប្រដាប់តែងព្រះនគរ ឲ្យធ្វើបាពំមណ្ឌបក្នុងព្រះរាជលាន ហើយទ្រង់ឡើងគង់លើព្រះរាជបល្ល័ង្ក ក្រោមស្វេតច្ឆត្រ ក្នុងមណ្ឌបដែលប្រដាប់តុបតែងដោយគ្រឿងអលង្ការមហាប្រសើរ មានពពួកអមាត្យហោមរោមជាបរិវារ ព្រះអង្គប្រុងប្រៀបនឹងសោយសុរា ៗ

គ្រានោះ សម្ដេចសក្កទេវរាជ ទ្រង់ប្រមើលមើលនូវសត្វលោកថា: "នរណាខ្លះហ្ន៎ ជាអ្នកប្រហែសធ្វេសក្នុងកុសលធម៌ទាំងឡាយ មានការ

---

១ បុរាណហៅថា ពាង, ប៉ូវ, កំប៉ុក. សម្រាប់បិទសុរា ៗ

បម្រើនូវមាតានឹងបិតាជាដើម! អ្នកណាខ្លះហ្ន៎ ជាអ្នកបំពេញនូវសុចរិតទាំង៣! សម្ដេចសហស្សន័យក៏បានឃើញនូវព្រះបាទសព្វមិត្ត កំពុងតែគង់ប្រុងប្រៀបនឹងសោយសុរា ព្រះអង្គទ្រង់ព្រះចិន្តាការថា: "បើព្រះបាទសព្វមិត្តនេះសោយសុរា មុខជាអ្នកជម្ពូទ្វីបទាំងអស់នឹងវិនាស បើដូច្នោះមានតែអញនឹងធ្វើស្ដេចនោះកុំឲ្យសោយសុរាបានអេះ" ហើយទ្រង់កាន់យកក្អមមួយ ដាក់សុរាពេញក្លែងភេទជាព្រាហ្មណ៍មកស្ថិតនៅឰដ៏អាកាសក្នុងទីចំពោះព្រះភក្ត្រព្រះរាជាហើយពោលនាយថា: "អ្នកទាំងឡាយចូរទិញក្អមនេះចុះ អ្នកទាំងឡាយចូរទិញក្អមនេះចុះ" ។ ព្រះបាទសព្វមិត្តបានទ្រង់ទស្សនាការឃើញនូវព្រាហ្មណ៍នោះ ស្ថិតនៅឰដ៏អាកាស ហើយនិយាយដូច្នោះ ក៏ទ្រង់មានព្រះបន្ទូលចរចាជាមួយនឹងព្រាហ្មណ៍នោះថា "ព្រាហ្មណ៍ឯងទើបមកពីណាហ្ន៎? ហើយទ្រង់ពោលបទព្រះគាថា ៣ ព្រះគាថាដូច្នេះថា:

១- កោ បាតុរាសិ តិទិវា នភម្ហិ
ឱភាសយំ សំវរី ចន្ទិមាវ
គត្តេហិ តេ រស្មិយោ និច្ឆរន្តិ
សតេរិតា(១) វិជ្ជុរិវន្តលិក្ខេ ៗ

---

១ ឧរេបរិយាយោត្ថកេ សតេរតាតិ បាឋោ ។

អ្នកឯងមកពីណា អ្នកមកអំពីពិភពនៃត្រៃត្រឹង្សឬកើតនៅក្នុងអាកាសនេះទេ ក៏បំភ្លឺក្រឹតឲ្យស្វាងរុងរឿង ដូចជាព្រះចន្ទដល់ម៉្លេះ? រស្មីនៃអ្នកដែលផ្សាយចេញអំពីខ្លួន ហាក់ដូចជាផ្លេកបន្ទោរឈ្មោះសតេរិតា ដែលលេចឡើងក្នុងកណ្តាលអាកាស ។

២ — សោ ឆិន្នកាំ ក្រមសី អយម្ហិ

វេហាសយំ គច្ឆសិ តិដ្ឋសី ច

ឥទ្ធី នុ តេ វត្ថុកតា សុភាវិតា

អនទ្ធគូនមបិ(១) ទេវតានំ ។

អ្នកឯងឥតមានខ្យល់ម៉ឹងឡើងទេ ប៉ុន្តែប្រព្រឹត្តទៅក្នុងអាកាសដ៏ពេលវើឪបាន អ្នកឯងទៅឬស្ថិតនៅក្នុងអាកាសវេហាស៍ក៏បាន រិទ្ធិដែលអ្នកឯងធ្វើឲ្យជាទីពឹង ( របស់ខ្លួន ) ដែលអ្នកឯងចំរើនហើយដោយល្អ ( ហាក់ដូចជាមិនមែនរិទ្ធិរបស់មនុស្ស ) ប្រហែលជារិទ្ធិរបស់ទេវតាដែលជាអ្នកមិនដែលដើរដើរទៅកាន់ផ្លូវឆ្ងាយទេដឹង(២) ។

៣ — វេហាសយំ គមមាគម្ម(៣) តិដ្ឋសិ

កុម្ភំ កិំ ហោជាតិ យថេតមត្ថំ

កោ វា តុវំ កិំ សប្បតាយ កុម្ភោ

អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ ។

---

១ ឧភេបិយហោន្តិ អនទ្ធគូនំ អបិ ។ ២ វេញ្ញាទាំងឡាយកើតមានដំណើរទៅកាន់ទីឆ្ងាយ រមែងហោះទៅតាមអាកាស ។ ៣ ឧភេបិយហោន្តិ សង្គមាគម្មាតិ បាឋោ ។

– អ្នកឯងឈានទៅក្នុងអាកាសវេហាស៍ ហើយឈរពោលនាយថា: “អ្នកទាំងឡាយចូរទិញក្អមចុះ” អ្នកឯងឈ្មោះអ្វី? ម្យ៉ាងទៀត ក្អមនេះជាក្អមអ្វី? ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ។

លំដាប់នោះ សម្តេចសក្កទេវរាជ បានទ្រង់ព្រះសន្ទនាការហើយ ទ្រង់មានព្រះបន្ទូលថា: “បើដូច្នោះសូមព្រះអង្គទ្រង់ព្រះសណ្តាប់ចុះ” ហើយទ្រង់សំដែងនូវទោសសុរាថា:

៨– ឆ សប្បិ កុម្ភោ ឆបិ តេលកុម្ភោ
ឆ ផាណិតស្ស ឆ មធុស្ស កុម្ភោ,
កុម្ភស្ស វដ្ឋានិ អឆប្បកានិ,
ទោសេ ពហូ កុម្ភគតេ សុណោថ ។

ក្អមនេះមិនមែនក្អមសប្បិ មិនមែនក្អមប្រេង មិនមែនក្អមស្ករអំពៅ មិនមែនក្អមទឹកឃ្មុំទេ, ទោសរបស់ក្អមនេះមានច្រើនប្រការ, សូមព្រះករុណា ទ្រង់ព្រះសន្ទនាការនូវទោសដ៏ច្រើនដែលមាននៅក្នុងក្អមនេះចុះ ។

៩– គលេយ្យ យំ បិត្វា, បតេបបាតំ
សោព្ភំ គុហំ ចន្ទនិយោឡិគល្លំ,
ពហុំបិ ភុញ្ជេយ្យ អភោជនេយ្យំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវសុរាឯណា ហើយដើរដួលសស្រួស, ធ្លាក់ចុះក្នុងជង្ហុក ក្នុងអណ្តូង ក្នុងរូង ក្នុងរណ្តៅជ្រាំ ក្នុងរំលុង, ហើយត្រូវការបរិភោគតែអាហារដែលមិនគួរបរិភោគជាច្រើន; អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

៦- យំ វេ(១) បិត្វា ចិត្តស្មិំ អនេសមានោ
អាហិណ្ឌតិ គោវ ភក្ខសាទី(២),
អនាថមានោ ឧបគាយតិ នច្ចតិ ច,
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវសុរាឯណា ហើយមិនបានជាឥស្សរៈលើចិត្ត (ចិត្តគិតយ៉ាងណា ក៏ប្រព្រឹត្តអាការកិរិយាដូច្នោះឥតមានប្រាជ្ញាជាគ្រឿងទប់ទល់ទៀយ) ដូចជាគោដែលស៊ីបាយសុរា តែស៊ីហើយកាលណា តែងជ្រក, មមកស្វែងរកអាហារក្នុងទីតែផ្តាស, អ្នកប្រមឹកនោះជាមនុស្សគ្មានទីពឹង បើបានឮគេច្រៀងក៏ចូលទៅច្រៀងផង បានឃើញគេរាំ ក៏ចូលទៅរាំផង, អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

៧- យំ វេ បិត្វា អចេលោវ នគ្គោ
ចរេយ្យ គាមេ វិសិខន្តរានិ

---

១ ឱភាបិយបោត្ថកេ វេសទ្ទោ ន ទិស្សតិ ។ ២ ឱភាបិយបោត្ថកេ ភក្ខសាទិ ។

សមុទ្ទក្ខិត្តោ អតិវេលសាយី (១)

តស្ស បុណ្ណំ កុម្ភមិមំ ភិណាថ ៗ

អ្នកផងផឹកនូវសុរាឯណា (គ្របបិទបាំងកេរ្តិ៍ខ្មាស) ជាមនុស្ស អាក្រាតដូចជាអចេលក: ហើយត្រេចទៅពាសស្រុកពាសផ្លូវថ្នល់ ជាមនុស្សមានចិត្តផេងផោង ដេកដើរហួសវេលា; អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ៗ

៨- យំ វេ បិត្វា ទុជ្ជាយ បវេធមានោ

សិសញ្ច ពាហុញ្ច បចាលយន្តោ

សោ នច្ចតិ ទារុកដល្លិកោវ

តស្ស បុណ្ណំ កុម្ភមិមំ ភិណាថ ៗ

បុគ្គលផឹកនូវសុរាឯណា ហើយក្រោកឡើងដ្រុលដ្រួសងក់ក្បាល ធ្លាដៃ រាំរែក (ទៅតាមតែបានឥតមានទំនួល) ហាក់ដូចជារូបយន្តដែលគេធ្វើដោយឈើ; អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ៗ

៩- យំ វេ បិត្វា អគ្គិទឌ្ឍា សយន្តិ

អថោ សិង្គាលេហិបិ ខាទិតាសេ

ពន្ធំ វធំ ភោគជានិញ្ចេត្តិ

តស្ស បុណ្ណំ កុម្ភមិមំ ភិណាថ ៗ

---

១ អតិវេលចារីតិបិ បាឋោ ។ (អដ្ឋកថា) ៗ

ជនទាំងឡាយផឹកនូវសុរាឯណា ហើយមានសេចក្ដីក្ដៅក្រហាយដូចជាភ្លើងឆេះ ដេកនៅក្នុងទីតែផ្ដាស សត្វទាំងឡាយមានបចកជាដើមទំពាស៊ីក៏មាន ប្រព្រឹត្តអនាចារផ្សេងៗ មានពាយ, កាប់ទឹងសម្លាប់គេជាដើម ដកបតែកជកា ចាប់ចងនាំទៅសម្លាប់ ឬរឹបជាន់ទ្រព្យសម្បត្តិអស់ទៅក៏មាន: អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

១០- យំ វេ បិត្វា ករេយ្យ អករណេយ្យំ,
សកាយមាសិណោ អបេតចិត្តោ
សមត្ថិតោ វត្តតោ ព្យសន្នោ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវសុរាឯណា ហើយពោលនូវតំនោលដែលគេមិនគប្បីពោល, ទុកជាអង្គុយនៅក្នុងពេងជាវប្រជុំក៏អាក្រាតសំពត់អាវ (មិនដឹងខ្លួន) ជាមនុស្សមានត្របកភ្នែកទន់ព្រឹមព្រំនៅក្នុងកំអួតរបស់ខ្លួន ហើយដល់នូវសេចក្ដីវិនាសផ្សេងៗ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១១ - យេ វេ បិត្វា ឧក្កដ្ឋោ អាវិលក្ខោ
មមេវ សព្វបឋវីតិ[១] មញ្ញតិ[២]

១ សព្វា បឋវីតិបិ បាឋោ (អដ្ឋកថា) ។ (២) ន មញ្ញេ ។

ន មេ សមោ ចាតុរន្តោបិ ភជោ;

តស្មា បុណ្ណំ កុម្ភមិមំ ភិណាថ ។

អ្នកផងផឹកនូវសុរាឯណា ហើយគ្រងក្រាងអួតអាងថា ខ្លួនជាអ្នកទានបានហានក្លា ឥតមាននរណាស្មើនឹងខ្លួនឡើយ ជាមនុស្សមានភ្នែកក្រហមជានិច្ច តែងមានសេចក្ដីសម្គាល់មើលងាយថា: ផែនដីទាំងមូលជារបស់អញ ទុកជាស្ដេចដែលជាឥស្សរៈលើផែនដីធំមានព្រំប្រទល់ដល់សមុទ្រទាំងបួន ក៏នៅតែមិនស្មើនឹងអញដែរ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១២ – ឆាតិមាឆា កាលបានំ បេសុណា[1]

ធុត្តិញ្ញាណិនំ ឧក្កយិនំ បលាយិនំ

ចោភណាធុត្តាន[2] គតី និកេតោ;

តស្មា បុណ្ណំ កុម្ភមិមំ ភិណាថ ។

ជនទាំងឡាយផឹកនូវសុរាឯណា ហើយធ្វើនូវជម្លោះព្រោះសេចក្ដីមើលងាយគេ ជាមនុស្សបេះបួយពោលពាក្យញុះញង់ ដើម្បីបំបែកបំបាក់គេ ជាមនុស្សមានសម្បុរអាក្រក់ អាក្រាតជាប្រក្រតី បើជួនជាខ្វាចអ្វីរត់ឥតបើគិត ឯលំនៅរបស់ជនទាំងនោះក៏ជាទីប្រជុំនៃពួកអ្នកលេងចាស់; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

---

១ ឱកេបិយ ពោត្ថកេ បេសុណកានិ ។ ២ ឱកេបិយ ពោត្ថកេ ហោភនំ ធុត្តានំ ។

១៣ - ឥទ្ធានិ ផីតានិ កុលានិ អស្សុ
អនេកសាហស្សធនានិ លោកេ
ឧច្ឆិន្នទាយជ្ជកតានិមាយ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ៗ

ត្រកូលដែលសម្រេចបរិបូណ៌ដោយបរិក្ខារ នឹងប្រដាប់ប្រដាផ្សេងៗ មានធនធានជាច្រើនពាន់, គេធ្វើត្រកូលដូច្នោះឲ្យអស់កេរ្តិ៍អាករ រលីងទៅបានព្រោះតែសុរានេះ; អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ៗ

១៤ - ធញ្ញំ ធនំ រជតំ ជាតរូបំ
ខេត្តំ គវំ យត្ថ វិនាសយន្តិ
ឧច្ឆេទនី វិត្តវតំ កុលានំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ៗ

ជនទាំងឡាយបំផ្លាញនូវសម្បត្តិផ្សេងៗ មានស្រូវ, ទ្រព្យ, ប្រាក់, មាស, ស្រែនឹងគោជាដើមឲ្យវិនាសទៅក្តី; ជាអ្នកផ្តិលផ្តាច់វង្សត្រកូលដែលធ្លាប់ប្រព្រឹត្តទៅកាន់សេចក្តីចំរើនឲ្យធ្លាក់ចុះទៅកាន់សេចក្តីវិនាសក្តី ព្រោះតែសុរាឯណា អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ៗ

១៥ - យំ វេ[១] បិតា ទុដ្ឋចោរ[២] ចោរោ

អក្កោសតិ បិតរំ មាតរញ្ច,

សស្សុំបិ[៣] គណ្ហោយ្យ អជោបិ សុណ្ហំ

តស្ស កម្មមិមំ កិណាថ ។

មនុស្សប្រុសស្ទួតបួត បានផឹកសុរាឯណា ហើយត្រឡប់ក្លាយជាមនុស្សរបើងរើងរួស ហ៊ានជេរប្រទេចផ្តាសាបិតាមាតា បើមានម្តាយក្មេក ហ៊ានចាប់ម្តាយក្មេក បើមានកូនប្រសា ហ៊ានចាប់កូនប្រសាសម្គាល់ថាជាភរិយារបស់ខ្លួន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៦ - យំ វេ បិតា ទុដ្ឋចោរី នារី

អក្កោសតិ សស្សុំ សាមិកញ្ច,

ទាសំបិ គណ្ហោ បរិចារិកាយ្យ;

តស្ស បុណ្ណំ កម្មមិមំ កិណាថ ។

មនុស្សស្រីស្ទួតបួត បានផឹកសុរាឯណា ហើយត្រឡប់ក្លាយជាមនុស្សរបើងរើងរួស ហ៊ានជេរប្រទេចផ្តាសាឪពុកក្មេកប្តីស្វាមី ភាន់ច្រឡំចាប់ខ្ញុំកំដរ សម្គាល់ថាជាស្វាមីរបស់ខ្លួន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

---

១ ឧភោបិយំបោត្ថកេ យំ ពេ បិតា ។ ២ ឱ ទុដ្ឋចោរោ ។ ៣ ឱ សស្សុំបិ ។

១៧- យំ វេ បិត្វាន ហនេយ្យ ទោសោ
ធម្មេ ឋិតំ សមណំ ព្រាហ្មណំ វា,
គច្ឆេ អបាយំបិ ឥតោ ចុតានំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនប្រុសស្រីផឹកសុរាឯណា ហើយបានសម្លាប់ នូវសមណព្រាហ្មណ៍ដែលស្ថិតនៅក្នុងសុចរិតធម៌, ក៏ធ្លាក់ទៅកើតក្នុងអបាយភូមិគឺៈ នរកប្រេត អសុរកាយ តិរច្ឆាន ព្រោះតែការសម្លាប់សមណព្រាហ្មណ៍នោះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៨- យំ វេ បិត្វា ទុច្ចរិតំ ចរន្តិ
កាយេន វាចាយ ច ចេតសា វា,
និរយំ វជន្តិ ទុច្ចរិតំ ចរិត្វា;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកសុរាឯណា ហើយប្រព្រឹត្តនូវទុច្ចរិតដោយកាយ, ដោយវាចាដោយចិត្ត, លុះប្រព្រឹត្តទុច្ចរិតគឺធ្វើអកុសលទាំង ១០ ប្រការ ដោយទ្វារទាំង ៣ ប្រការយ៉ាងនេះហើយ ក៏ធ្លាក់ចុះទៅកើតក្នុងនរក; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៩ - យំ យាចមានា ន លភន្តិ បុព្វេ
ពហុំ ហិរញ្ញំបិ បរិច្ចជន្តា,
សោ តំ បរិត្តា អលភំ ភណាតិ;
តស្សា បុណ្ណំ កុម្ភមិមំ ភិណាថ ៗ

បុរសស្ត្រីទាំងឡាយឯណា កាលដើមឡើយជាមនុស្សពោលពាក្យសត្យប្រាកដប្រជា ទុកជានរណាមួយឲ្យប្រាក់សំណូកជាច្រើន ហើយអង្វរគេថាៈ “សូមអ្នកនិយាយកុហកបន្តិចចុះ” ដូច្នេះក៏នៅតែមិនបាន លុះបុរសស្ត្រីនោះបានផឹកសុរាវេលាណា ក៏រមែងពោលពាក្យលេះលោះ មិនសមហេតុ-ផល តាំងពីវេលានោះមក អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ៗ

២០ - យំ វេ បិត្វា បេសនោ[១] បេសយន្តោ[២],
អច្ចាយិកេ ការិយម្ហិ ជាតេ[៣],
អត្តម្បិ សោ នប្បជានាតិ វុត្តោ;
តស្សា បុណ្ណំ កុម្ភមិមំ ភិណាថ ៗ

កាលបើមានការរួសរាន់កើតឡើង គេប្រើប្រែសណិយបុរស (បុរសដើរសារ) ដែលផឹកសុរា ឲ្យទៅដើម្បីបញ្ជាក់សេចក្ដីដល់អ្នកឯណោះ ៗ

---

១ ឧភោបិយ បោត្ថកេ បរិត្វា បេសនេ បេសិយន្តោតិ ជាហោ ៗ ២ ឧ. បេសិយន្តោ ៗ
៣ ឧ. ជាតេតិ ជាហោ, សោ ន យុត្តោ ៗ

សួរថា: អ្នកឯងមកមានការអ្វី ? ក៏មិនដឹងសេចក្ដីអ្វីសោះ ព្រោះស្រវឹងស្រាស្ដាប់ពាក្យបណ្ដាំមិនបាន; អ្នកទាំងឡាយចូរវៀរញក្ដមនេះ ដែលពេញទៅដោយស្រានោះចុះ ។

២១ - ហិរីមនា អហិរីកកាវំ

ចាតុំ គេហេត្វិ មទនាយ[1] មត្តា,
ធីរាបិ សន្តា ពហុកំ ភណន្តិ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយ ទុកជាមានចិត្តប្រកបដោយហិរិ (សេចក្ដីអៀនខ្មាស) យ៉ាងណាក៏ដោយ តែស្រវឹងស្រាហើយ ក៏ធ្វើនូវកាពនៃខ្លួនជាមនុស្សមិនមានហិរិ ឲ្យប្រាកដជាក់ស្ដែងដល់ភ្នែកអ្នកទាំងពួង, ឯលោកអ្នកប្រាជ្ញទាំងឡាយជាសប្បុរស មានសន្ដានស្ងប់ស្ងាប់រមែងពោលពាក្យដ៏វៀលជាច្រើន, អ្នកទាំងឡាយចូរវៀរញក្ដមនេះ ដែលពេញទៅដោយស្រានោះចុះ ។

២២ - យំ វេ បិត្វា ឯកថូបា សយន្តិ
អនាសកា ថណ្ឌិលទុក្ខសេយ្យំ[2]
ទុព្វណ្ណិយំ អាសយគ្យញ្ញបេត្តិ[3]
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

---

១ ឱ. មទិបាយាគិ ញាយោ ។ ២ ឱកេបិយលោត្តកេ សយ្យា ។ ៣ ឱ. អាយសក្កញ្ចុបេន្តិ ។

មនុស្សដ៏ថ្លៃថ្លាទាំងឡាយ ផឹកនូវសុរាឯណា ហើយដេកប្រគាក់ប្រគង់ប្រគុំគ្នា នឹងមនុស្សមានជាតិថោកទាបដូចជាកូនជ្រូក, កាលពីដើមជាមនុស្សបរិបូណ៌ដោយគោធនាហារ នឹងលំនៅ ក៏ត្រឡប់ទៅជាមនុស្សឥតអាហារ ដេកកើតទុក្ខលើផែនដី ជនប្រុសស្រីមែងថ្លែងសេចក្ដីសកេរ្តិ៍ដ៏អាក្រក់ៗ គេតែងតិះដៀល ដោយដំនៀលផ្សេងៗ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៣- យំ វេ បិត្វា បតក្ខន្ធា សយន្តិ
តាភេ ក្សជហាតារិ, ឆ ហិ
ភារុណិយា វេគា ឆវេក សុស្សហោរិវ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកសុរាឯណា ហើយទន់ករដៀកដេកនៅ ដូចជាគោដែលមនុស្សកំណាចទាក់ដោយខ្សែព្រួរហើយនាំទៅ រមិនស៊ីស្មៅ មិនផឹកទឹក ដូច្នោះឯង, ឯកម្លាំងសុរា ឥតមាននរណាប្រឹងប្រែងទប់ទល់បានឡើយ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៤- យំ មនុស្សា វិវត្តិ សព្វំ
យោវសមិវ, តំ ហោតោ វិសសមានំ

កោ ឯកោ ចាតុមហារតិ;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សទាំងឡាយដែលជាអ្នកដឹងសេចក្តីខុសត្រូវ រមែងវៀរលែងនូវសុរាឯណា ដូចជាគេវៀរវាងសត្វពស់ដែលមានពិសដ៏ពន្លឹក, នរណាហ្ន៎ ទើបគួរដើម្បីផឹកនូវសុរានោះ ដែលប្រហែលគ្នានឹងពស់មានពិសក្លៀវក្លាដូច្នោះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៥— យំ វេ បិត្វា អន្ធកវេណ្ហុបុត្តា[១]
សមុទ្ទតីរេ បរិចារយន្តា
ឧបក្កមុំ មុសលេហាញ្ញមញ្ញំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

កាលពីដើម មានព្រះរាជបុត្រក្សត្រជាបងប្អូននឹងគ្នា ១០ ព្រះអង្គ កាលដែលពួករាជសេវកៈកំពុងបម្រើ នៅទៀបឆ្នេរសមុទ្រ ក៏ទ្រង់ប្រហារគ្នានឹងអង្រែទៅវិញទៅមក ព្រោះតែផឹកនូវសុរាឯណា, អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៦— យំ វេ បិត្វា បុព្វទេវា បមត្តា
តិទិវា ចុតា សស្សតិយា សមាយា,

---

១ ឱ. អន្ធកវេណ្ហុបុត្តា ។

តំ តាទិសំ មដ្ឋមិមំ និរត្ថកំ
ជានំ មហារាជ កថំ បិវេយ្យ ។

ពួកអសុរទាំងឡាយមានសេចក្ដីប្រមាទហើយច្យុតចាកតាវតឹង្សទេវលោកដែលលោកសន្មតថាជាទីទៀង ព្រោះមិនសូវប្រែប្រួលដោយសេចក្ដីស្លាប់កើត ធ្លាក់មកព្រមទាំងពួកអសុរមាយាស្ទួមស្រិគ្គាផង ព្រោះតែផឹកនូវសុរាឯណា, បពិត្រមហារាជ បណ្ឌិតបុរសជាអ្នកមានប្រាជ្ញាប្រែហែលព្រះអង្គ កាលបើជ្រាបថាសុរានោះជាទឹកឥតប្រយោជន៍យ៉ាងនេះហើយនឹងសោយសុរានោះម្ដេចកើត ។

២៧- នយិមស្មឹ កុម្ភស្មឹ ទធិ មធុវា
ឯវំ អភិញ្ញាយ ករោហិ រាជ,
ឯវញ្ហិ មំ កុម្ភគតា(១) មយា តេ
អក្ខាតរូបំ តវ សព្វមិត្តាតិ ។

ទធិក្ដី, ទឹកឃ្មុំក្ដី មិនមានក្នុងក្អមនេះទេ, បពិត្រព្រះរាជា ព្រះអង្គបានជ្រាបច្បាស់យ៉ាងនេះហើយ សូមទិញក្អមនេះចុះ, ឯទោសដែលមាននៅក្នុងក្អមរបស់ខ្ញុំយ៉ាងនេះ ខ្ញុំបានថ្វាយព្រះអង្គសព្វគ្រប់ហើយ, បពិត្រព្រះបាទសព្វមិត្ត ពាក្យដែលខ្ញុំបានពោលថ្វាយព្រះអង្គ ជាពាក្យពោលតាមសេចក្ដីពិត ។

១ កុម្ភគតា មយាតិ កុម្ភគតំ មយាតិ អយមេវ វា បាឋោ ។ (អដ្ឋកថា) ។

ព្រះមហាក្សត្របានទ្រង់ព្រះសវនាការសេចក្តីនោះសព្វគ្រប់ហើយ ទ្រង់ជ្រាបច្បាស់នូវទោសនៃសុរា ទ្រង់មានព្រះទ័យត្រេកអរហើយទ្រង់ធ្វើជោមនាការ សរសើរសម្តេចសក្កទេវរាជ ហើយពោលព្រះគាថា ២ ព្រះគាថាដូច្នេះថា:

២៨ - ត្វំ មេ បិតា ច អថបិ មាតា

ឋតានិសោ យានិសតោ ត្វំ-សិ

ហិតានុកម្បី បរមត្ថកាមោ,

សោហំ ករិស្សំ វចនំ តវជ្ជ ។

២៩ - ទទាមិ តេ គាមវរានិ បញ្ច

ទាសីសតំ សត្ត គវំ សតានិ

អាជញ្ញយុត្តេ ច រថេ ទស ឥមេ

អាចរិយោ ហោសិ មមត្ថកាមោតិ ។

អ្នកឯងនេះជាបិតាឬជាមាតារបស់ខ្ញុំក៏ទេដែរ, ប៉ុន្តែជាអ្នកអនុគ្រោះខ្ញុំដោយពាក្យសំដីដ៏មានប្រយោជន៍ ជាអ្នកប្រាថ្នានូវប្រយោជន៍ដ៏ឧត្តមដល់ខ្ញុំ, តាំងពីថ្ងៃនេះតទៅ ខ្ញុំនឹងធ្វើតាមពាក្យអ្នក ឥឡូវនេះខ្ញុំសូមជូនស្រុកសួយប្រាំស្រុក ដែលមានសួយឡើង ១ សែនៗក្នុង ១ ឆ្នាំៗ និងខ្ញុំស្រី ១ រយ គោ ៧ រយ រថដែលទឹមដោយសេះអាជានេយ ១ គូៗ តាំង

១០ នេះដល់អ្នកឯង, អ្នកឯងដែលជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ សូមតាំងខ្លួនជាគ្រូអាចារ្យខ្ញុំចុះ ៗ

សម្ដេចសក្កទេវរាជបានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ក៏សំដែងនូវអត្តភាពជាទេវតាវិញ ឲ្យព្រះរាជាស្គាល់ខ្លួនហើយស្ថិតនៅឰដអាកាស ទ្រង់ពោលព្រះគាថា ២ ព្រះគាថាដូច្នេះថា:

៣០- តវេវ ទាសីសតមត្ថុ រាជ,
គាវា ច គាវេ ច តវេវ ហោន្តុ
អាជញ្ញយុត្តា ច រថា តវេវ,
សក្កោហមស្មិ តិទសានមិន្ទោ ៗ

៣១- មំសោចនំ សព្វធាយន្តុ កុញ្ជេ(១)
ទានស្ស ច ត្វំ មធុមាសព្វេ,
ឯវំ ត្វំ ធម្មរតោ ជនិន្ទ
អនិន្ទិតោ សគ្គមុបេហិ ឋានន្តិ ៗ

បពិត្រព្រះរាជា ទាសីទាំង ១០០ សូមជារបស់ព្រះអង្គវិញចុះ, ខ្លួនខ្ញុំឈ្មោះសក្កជាធំតូចដ្រ្ទាធិបតីនៃទេវតាក្នុងពិភពពនៃត្រៃត្រឹង្សមិនសមួងចង់បានសម្បត្តិរបស់ព្រះអង្គប៉ុណ្ណោះទេ ៗ សូមតែព្រះអង្គកុំសោយសុរា សូម

១ ឱ. កុញ្ជ ៗ

ក្សត្រទ្រង់សោយតែក្រយាស្ងោយដែលប្រកបដោយម្ហូបតាមធម្មតា ទឹង ទឹកសប្បូរវិញ បើសព្វព្រះទ័យចំណីឈ្ងុយឆ្ងាញ់ សូមព្រះអង្គទ្រង់សោយនំសណ្ដែកដែលលាយដោយទឹកឃ្មុំចុះ, បពិត្រព្រះជនិទ្ធពិនភាព បើព្រះករុណាវៀរបង់មិនទ្រង់សោយសុក ហើយក្សត្រាទ្រង់សោយតែក្រយា-ស្ងោយដែលមានរសដ៏ប្រសើរផ្សេង ៗ ទ្រង់លះលែងទុច្ចរិតទាំង ៣ មានព្រះទ័យត្រេកអរចំពោះសុចរិតធម៌ទាំង ៣ ប្រការយ៉ាងនេះហើយ ឥតមាននរណានិន្ទាព្រះអង្គបានឡើយ ហើយព្រះអង្គនឹងបានទៅកើតក្នុងឋានសួគ៌ទៀត ។

សម្ដេចសក្កទេវរាជ ទ្រង់ប្រទានឱវាទដល់ព្រះបាទសព្វមិត្តនោះដូច្នោះហើយ ក៏ត្រឡប់ទៅលំនៅរបស់ព្រះអង្គវិញ ។

ឯព្រះបាទសព្វមិត្តនោះវិញ ក៏ឈប់សោយសុក ក្សត្រាទ្រង់ឲ្យទម្លាយភាជនៈសម្រាប់ដាក់សុកចេញអស់ ហើយទ្រង់សមាទានសីល ៥ សីល ៨ ចក្រីទ្រង់បរិច្ចាគព្រះរាជទ្រព្យឲ្យទៅជាទានដល់សមណព្រាហ្មណាចារ្យ នឹងស្មូមយាចកអ្នកកំសត់ទុគ៌តជាច្រើនហើយព្រះអង្គទ្រង់គង់នៅដរាបដល់សោយព្រះវិលាល័យក្ស័យព្រះជន្មទៅ បានទៅយកព្រះជាតិកំណើតកើតនៅក្នុងឋានសួគ៌ ។

ឯសុកក៏កើតឡើងជាលំដាប់ ៗ ផ្សាយពាសពេញទាំងជម្ពូទ្វីបតាំងពីកាលនោះមក ។

សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំមកនូវព្រះធម៌ទេសនានេះ ហើយ ទ្រង់ប្រជុំជាតកថា: ព្រះបាទសព្វមិត្តនោះ លុះបរិវត្តមក បានជាភិក្ខុឈ្មោះអានន្ទ ឯសក្កទេវរាជ គឺជាតួអង្គតថាគតនេះឯង ។

កុម្ភជាតកំ និដ្ឋិតំ ។

ចប់កុម្ភជាតកតែប៉ុណ្ណោះ ។

# រឿងស្ត្រីស្មោះត្រង់នឹងស្វាមី

មាននិទានមួយដំណាលថា នៅក្នុងនគរមួយនោះ មានសេដ្ឋីពីរនាក់ សេដ្ឋីម្នាក់មានកូនស្រី សេដ្ឋីម្នាក់ទៀតមានកូនប្រុស ទើបសេដ្ឋីទាំងពីរ គិតផ្សំផ្គុំកូនប្រុស-ស្រីរបស់ខ្លួនឲ្យបានជាស្វាមីភរិយា ៗ គាប់ប្អូនជានគរនោះកើតចលាចល បះបោរឡើង ហើយសេដ្ឋីទាំងពីរនាក់ក៏បាក់បែកខ្ចាត់ខ្ចាយចេញទៅនៅទីទៃៗពីគ្នា តមកសេដ្ឋីមានកូនស្រីនោះក៏ផ្សំផ្គុំកូនស្រីឲ្យមានប្តីនឹងបុរសដទៃទៅ កូនស្រីក៏ព្រមទទួលយកជាប្តីពុំប្រកែក លុះនាងបានទៅនៅនឹងប្តីហើយ ទើបនាងស្រដីនឹងប្តីថា ដ្បិតឪពុកខ្ញុំបានផ្សំផ្គុំខ្ញុំឲ្យមានប្តីអំពីមុនរួចហើយ តែពុំទាន់បានមូលលំនៅស្ថាន ស្រាប់តែអ្នកបានខ្ញុំមកជាភរិយា ហើយខ្ញុំពុំទាន់បានដោះប្តេជ្ញានឹងប្តីមុននោះនៅឡើយ ឥឡូវនេះខ្ញុំសូមលាអ្នក ទៅដោះប្តេជ្ញានឹងប្តីដើមនោះសិន បើអម្ចាស់បើកទើបខ្ញុំហ៊ានទៅ បើអម្ចាស់ពុំបើកឲ្យទៅទេ ខ្ញុំពុំហ៊ានទៅឡើយ ៗ

ឯប្តីនោះឆ្លើយថា អញគិតថានាងជ្រះស្រឡះទំនេរឥតប្តីទេ បើនាងមានស្វាមីអំពីមុនរួចមកហើយដូច្នោះ ចូរនាងទៅដោះប្តេជ្ញានឹងប្តីដើមឲ្យជ្រះស្រឡះសិនចុះ អញពុំឃាត់ខាំងនាងឡើយ ៗ លុះនាងបានអនុញ្ញាតពីប្តីដូច្នោះហើយ ក៏តាក់តែងស្អិតស្អាងរាងកាយ ប្រដាប់គ្រឿងសម្រាប់អាត្មារួចស្រេចហើយ ក៏លីលាចេញទៅ សំដៅស្មោះ

ចំពោះរកកូនសេដ្ឋីជាប្ដីដើមនោះ ស្រាប់តែទៅពើបពះប្រទះនឹងខ្លាធំអត់អាហារមក ៧ ថ្ងៃហើយ ទើបខ្លាលោតទៅប្រឹងនឹងចាប់នាងធ្វើចំណែកអាត្មា ។ នាងក៏ភ័យរៀងនាងឲ្យខ្លាស្ដាប់សព្វគ្រប់ ខ្លាក៏លែងបើកឲ្យនាងត្រេចទៅដោយស្រួល ។

ឯនាងរំស្រូតដើរ គត់ពីនោះចន្លិចមកក្បូវ ស្រាប់តែចួបប្រទះនឹងចោរ ៧ នាក់ ចោរយល់នាងនោះមានគ្រឿងប្រដាប់សម្រាប់អាត្មាសឹងជារបស់មានដំថ្លៃ ទើបចោរគិតគ្នានឹងទៅចាប់នាងយកអីវ៉ាន់អស់នោះ ។ នាងក៏និយាយសារស័ព្ទប្រាប់ចោរតាមដំណើរសព្វគ្រប់ ពួកចោរបានស្ដាប់ដូច្នោះ ក៏មិនយកទ្រព្យទាំងនោះឡើយ ហើយបើកឲ្យនាងទៅដោយស្រួល ។

នាងបានរួចរបូតពីកណ្ដាប់ដៃចោរដូច្នោះហើយ ក៏ដើរត្រេបង្កើតទៅរហូតដល់លំនៅប្ដីដើមនោះ ។ ក៏សួរថា នាងមកអំពីទីតំបន់ណា ? នាងអង្គុយនាស្ថានដ៏សមគួរហើយ ដំរាបថា អាពុកខ្ញុំជាសេដ្ឋីបានផ្ដុំផ្គុំខ្ញុំឲ្យជាភរិយាអ្នកអំពីមុនរួចមកហើយ ឥឡូវនេះ អាពុកខ្ញុំលើកខ្ញុំឲ្យមានប្ដីនឹងបុរសដទៃទៀត ឯខ្ញុំពុំទាន់បានក្រាបលា បេ្ដជ្ញានឹងអ្នកជាប្ដីដើម ឲ្យបានជ្រះស្រឡះ ដូច្នេះបើម្ចាស់បើកឲ្យខ្ញុំទៅខ្ញុំក៏ទៅ បើអម្ចាស់ពុំព្រមបើកឲ្យទៅទេ ខ្ញុំពុំហ៊ានទៅឡើយ ។

ឯចៅនោះឆ្លើយឡើងថា នាងមានចិត្តស្មោះចំពោះមកដល់អញ ។

អណោស់ តែឥឡូវនេះអាពុកនាងលើកនាងឲ្យមានប្ដីហើយ អញនឹងទៅតវ៉ាប្រាថ្នានាងជាប្រពន្ធពុំបានឡើយ ចូរនាងទៅកាន់ប្ដីនាងហោង ៗ ទើបនាងក្រាបលាចៅនោះត្រឡប់ទៅផ្ទះវិញ ៗ

គាប់ជួនជានាងដើរមក តាមផ្លូវស្រាប់តែចោរប្រទះនឹងចៅម្នាក់កំពុងដើរទេសរកប្រពន្ធ បានឃើញនាងមានរូបឆោមស្អាងស្អាត មានទាំងគ្រឿងប្រដាប់ដ៏ល្អនៅនឹងខ្លួន ទើបចៅនោះនិយាយបែបចង់ប្រាថ្នានឹងយកនាងជាប្រពន្ធ ៗ ឯនាងក៏ថ្លែងសេចក្ដីប្រាប់ដោយដំណើររឿងតាំងពីដើមរៀងមក ចៅនោះក៏ពុំដែលតវ៉ាប្រាថ្នានាងនោះឡើយ លុះនាងបានទៅដល់លំនៅប្ដីហើយ ក៏នៅរួមគ្នាជាសុខក្សេមក្សាន្តតរៀងទៅ ៗ

នៅទីបំផុតនៃនិទានរឿងនេះ មានសេចក្ដីពោលទុកថា បើអ្នកឯណាសរសើរចិត្តប្ដីរបស់នាងនោះ ហេតុតែអ្នកនោះជាមនុស្សច្រើនប្រ-ពន្ធ បើអ្នកឯណាសរសើរចិត្តខ្លា ហេតុតែអ្នកនោះជាមនុស្សគាប់ចិត្តបៀតបៀនបំបាត់ជីវិតគេ ៗ បើអ្នកឯណាសរសើរចិត្តចោរទាំង ៧ នោះ ហេតុតែអ្នកនោះជាមនុស្សមានចិត្តលោភចង់បានតែទ្រព្យគេ ៗ បើអ្នកឯណាសរសើរប្រុសដើរទេសរកប្រពន្ធនោះ ហេតុតែអ្នកនោះជាមនុស្សចូលចិត្ត ប្រព្រឹត្តបរទារកម្មនឹងភរិយាគេ ៗ បើអ្នកឯណាទីមួយវៀរក្ដីទាំង ៤ ចំពូកនេះបានអ្នកនោះនឹងបានឆ្លងរំលងទៅដល់ - ស្ថានសួគ៌ានាយហោង ៗ

ចប់រឿងស្ត្រីស្មោះត្រង់នឹងស្វាមីតែប៉ុណ្ណោះ ៗ